# មិត្តនគរបាល
POLICEFRIENDSHIPMAGAZINE

ទស្សនាវដ្ដី
លេខ ១០១/ កញ្ញា-តុលា / ២០២១

## អរគុណសន្តិភាព









យើងត្រូវរួមគ្នាទៅទទួលការចាក់វ៉ាក់សាំងប្រឆាំងកូវីដ១៩ តាមការកំណត់របស់ រាជរដ្ឋាភិបាលផង រួមគ្នាបន្តអនុវត្ត ៣ការពារ និង ៣កុំ ផង ដើម្បីខ្លួនយើង ក្រុមគ្រួសារយើង និងសង្គមជាតិយើង

# គណៈកម្មការនិពន្ធ

**នាយកគ្រប់គ្រង**

**ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត ម៉ៅ ប៊ុនណារិន**

**និពន្ធនាយក**

ឧត្តមសេនីយ៍ឯក សៀង សុវត្ថិ

**និពន្ធនាយករង**

ឧត្តមសេនីយ៍ទោ ប៉ុក សុជាតិ

វរសេនីយ៍ឯក ប៉ុក រដ្ឋា



**យកព័ត៌មាន និពន្ធ**

-វរសេនីយ៍ទោ ចាប ភ័ស្ត (ប្រធានក្រុម)

-វរសេនីយ៍ត្រី ប៉ុក គន្ធារ៉ូ

-អនុសេនីយ៍ឯក គន សេរី

**ថតរូប**

-វរសេនីយ៍ទោ ជិន ម៉ូលីដា (ប្រធានក្រុម)

-អនុសេនីយ៍ឯក ស្រ៊ី ឈុនឡេង

-អនុសេនីយ៍ឯក លន់ ឈាងសេង

-អនុសេនីយ៍ឯក ព្រំ ចាន់តារា

**ចែកផ្សាយ**

-វរសេនីយ៍ទោ ង៉ាន សុផាប (ប្រធានក្រុម)

-វរសេនីយ៍ត្រី សុន សៀង

**រចនាទំព័រ**

-អនុសេនីយ៍ឯក ម៉ុង រិទ្ធី (ប្រធានក្រុម)

-អនុសេនីយ៍ឯក អ៊ុន ពិសិទ្ធ

**ពិនិត្យអក្ខរាវិរុទ្ធ**

-វរសេនីយ៍ទោ ញ៉ឹម ហឿន (ប្រធានក្រុម)

-អនុសេនីយ៍ឯក វ៉ាន់ វិបុល

**កីឡា និងសិល្បៈ**

-វរសេនីយ៍ត្រី ជឹម ធី (ប្រធានក្រុម)

-អនុសេនីយ៍ឯក មុត សីហា





# មាតិកា

## ព័ត៌មានថ្នាក់ដឹកនាំ


១-សម្តេចក្រឡាហោម អញ្ជើញដឹកនាំប្រតិភូ.............០១

២-ឯកសារសំខាន់ៗចំនួន ៣ ត្រូវបានអនុម័ត.............០៣

៣-កិច្ចប្រជុំលើកទី ១៩ ដើម្បីពិនិត្យសេចក្តីព្រៀង....... ០៧

៤-ក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខ.............០៩

៥-ឆមាសទីមួយឆ្នាំ២០២១ គ្រោះថ្នាក់ចរាចរណ៍..........១៣

៦-សម្តេចក្រឡាហោម អនុញ្ញាតឱ្យប្រធានស្ថាន.........១៥

៧-អភិបាលខេត្តចំនួន ៧រូប ត្រូវបានផ្ទេរភារកិច្ច...........១៧

៨-ឯកឧត្តម ប៉ៅ ឆនិន អតីតអភិបាលខេត្ត.................១៩

៩-កិច្ចប្រជុំលើកទី១១ ស្តីពីកិច្ចសហប្រតិបត្តិការ..........២១

១០-កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី ...............២៣

១១-ពិធីប្រគល់-ទទួលសម្ភារបរិក្ខាបច្ចេកទេស............២៥

១២-កិច្ចប្រជុំសប្តាហ៍បច្ចេកវិទ្យាអន្តរជាតិសិង្ហបុរី........២៧

១៣-អគារស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិ..............២៩

១៤-កិច្ចប្រជុំពិនិត្យ និងពិគ្រោះយោបល់.....................៣១

១៥-អគ្គនាយកដ្ឋានពន្ធនាគារទទួលរថយន្ត................ ៣៣

១៦-ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ូ សាគុណ............៣៥

១៧-ឯកឧត្តម នាយឧត្តមសេនីយ៍ កែវ វណ្ណថន.............៣៧

១៨-កិច្ចប្រជុំរៀបចំផែនការមេសម្រាប់អភិវឌ្ឍន៍..........៣៩


## អត្ថបទសុខភាព


១-ខ្ទឹម ទឹកឃ្មុំ និងក្រូចឆ្មា ជួយបំបាត់អាការៈ.......................៤៣

២-ការញ៉ាំទឹកក្តៅមួយកែវរាល់ព្រឹក គឺជួយរំលាយ....................៤៤


## អត្ថបទស្រាវជ្រាវ


១-សង្គ្រោះផែនដី គឺសង្គ្រោះជីវិតយើង................................៥១


## សកម្មភាពសមាគមមិត្តនគរបាលជាតិកម្ពុជា


១- ប្រគល់ថវិកា ស ម ន...................................................៥៧


## កំណាព្យ


១- សញ្ជាតិតែមួយ..........................................................៥៦


## ប្រលោមលោក


១- បំភ្លេចមិនបាន.........................................................៥៩

# សម្តេចក្រឡាហោម អញ្ជើញដឹកនាំ គោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា











៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

# ប្រតិភូក្រសួងមហាផ្ទៃ ដាក់កម្រងផ្កា
# ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ





នៅព្រឹកថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០២១ នេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំប្រតិភូថ្នាក់ដឹកនាំក្រសួង ដាក់កម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណា **ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ។

គួររំលឹកថា៖ ព្រះករុណា **ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ បូរណភាពទឹកដី និង ឯកភាពជាតិខ្មែរ បានយាងសោយព្រះទីវង្គត កាលពីថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២ ។ ប្រជារាស្ត្រទូទាំងប្រទេស ព្រមទាំង មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ថ្នាក់មានក្តីអាណោះអាល័យ និងសម្តែងនូវការគោរពដឹងគុណដ៏ខ្ពង់ខ្ពស់បំផុតថ្វាយចំពោះ **ព្រះបរមរតនកោដ្ឋ** ដែលព្រះអង្គបានលះបង់ និងបូជាព្រះកាយពលដ៏ធំធេងចំពោះជាតិមាតុភូមិកម្ពុជា ៕











៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឯកសារសំខាន់ៗចំនួន ៣ ត្រូវបានអនុម័តក្នុង ឆ្លងដែន លើកទី ១៥ ក្រោមប្រធានបទ «យើងយកចិត្ត





កាលពីថ្ងៃទី២៨-៣០ ខែកញ្ញា ឆ្នាំ២០២១ កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន លើកទី១៥ (១៥th AMMTC) បានប្រារព្ធធ្វើឡើងតាមប្រព័ន្ធវីដេអូ ដឹកនាំដោយប្រទេសព្រុយណេ ដែលជាប្រធានកិច្ចប្រជុំនៅក្នុងឆ្នាំ២០២១នេះ ។

សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្នុងនាមជារដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ចូលរួមកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ និងបានផ្លាស់ប្តូរយោបល់ជាមួយបណ្តារដ្ឋសមាជិកអាស៊ាន ដោយនៅក្នុងកិច្ចប្រជុំនោះ **សម្តេចក្រឡាហោម** បានកោតសរសើរចំពោះស្មារតីជួយគ្នាទៅវិញទៅមករវាងរដ្ឋសមាជិកអាស៊ាន ក្នុងគ្រាដ៏លំបាកបង្ក



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី អាស៊ាន ទទួលបន្ទុកឧក្រិដ្ឋកម្ម ទុកដាក់ យើងត្រៀមលក្ខណៈ យើងរីកចម្រើន »





ឡើងដោយជំងឺកូវីដ-១៩ ដែលស្ថានភាពនេះដើរស្របទៅនឹងប្រធានបទរបស់អាស៊ានឆ្នាំ២០២១ គឺ«**យើងយកចិត្តទុកដាក់ យើងត្រៀមលក្ខណៈ:យើងរីកចម្រើន** »។ **សម្តេចក្រឡាហោម** ក៏បានថ្លែងអំណរគុណ និងអបអរសាទរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសព្រុយណេ ដែលបានជំរុញយន្តការនានា របស់AMMTC ជាពិសេសកិច្ចពិគ្រោះយោបល់ជាមួយប្រទេសដៃគូសន្ទនាឱ្យមានដំណើរការយ៉ាងរស់រវើក និងទទួលបានលទ្ធផលជាផ្លែផ្ការួមចំណែកយ៉ាងសំខាន់ដល់ការងារប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ក្នុងគោលដៅកសាងតំបន់អាស៊ាន ប្រកបដោយសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍ ។

**សម្តេចក្រឡាហោម** ក៏បានចូលរួមផ្លាស់ប្តូរទស្សនៈ និងគាំទ្រចំពោះការ

☞ ០៥



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



តមកពីទំព័រ ០៤

**ឯកសារសំខាន់ៗ ចំនួន ៣ ត្រូវបានអនុម័ត.....**





វាយតម្លៃរបស់បណ្ដារដ្ឋសមាជិកអាស៊ាន អំពីស្ថានភាពនៃឧក្រិដ្ឋកម្មឆ្លងដែននៅក្នុងតំបន់ ជាពិសេសការសម្ដែងនូវការព្រួយបារម្ភចំពោះការឆ្លៀតឱកាសកេងប្រយោជន៍ពីទំនើបកម្មនៃបច្ចេកវិទ្យាយកមកប្រើប្រាស់ជាមធ្យោបាយក្នុងការប្រព្រឹត្តអំពើខុសច្បាប់ ដែលនាំដល់ការកើនឡើងនូវបទល្មើសមួយចំនួននៃឧក្រិដ្ឋកម្មឆ្លងដែន ដូចជា៖ អំពើហិង្សាជ្រុលនិយម អំពើភេរវកម្ម អំពើរត់ពន្ធមនុស្ស អំពើជួញដូរមនុស្ស បទល្មើសបច្ចេកវិទ្យា ការជួញដូរគ្រឿងញៀន និងការជួញដូរសត្វព្រៃ និងឈើខុសច្បាប់ជាដើម ។

ក្នុងនាមរដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនអាស៊ាន **សម្ដេចក្រឡាហោម** ក៏បានបញ្ជាក់ជូនអង្គប្រជុំអំពីការប្ដេជ្ញាចិត្តរបស់កម្ពុជា ក្នុងការចូលរួមចំណែកជាមួយរដ្ឋសមាជិកអាស៊ានទាំងអស់ក្នុងភាពជាដៃគូដ៏ស្អិតរមួត ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ទម្រង់ ដោយប្រើប្រាស់គ្រប់**លទ្ធភាព និងមធ្យោបាយ តាមរយៈការអនុវត្តយន្តការថ្នាក់ជាតិ យន្តការទ្វេភាគី ពហុភាគី និងថ្នាក់តំបន់ ដើម្បីកសាងបាននូវកម្លាំងរួមមួយដ៏មានសក្ដានុពលក្នុងការដោះស្រាយបញ្ហាប្រឈម និងគំរាមកំហែងនានាពីឧក្រិដ្ឋកម្មឆ្លងដែន ។**

ក្រៅពីការផ្លាស់ប្ដូរទស្សនៈទៅវិញទៅមកលើសភាពការណ៍ឧក្រិដ្ឋកម្មឆ្លងដែន កិច្ចប្រជុំពេញអង្គថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែន ក៏បានអនុម័តឯកសារចំនួន ០៣ រួមមាន៖

**១-ឯកសារទស្សនទាន ស្ដីពី ផែនការបង្ហាញផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការគ្រប់គ្រងព្រំដែនអាស៊ាន**



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







**២-សេចក្តីប្រកាសអាស៊ាន ស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែនដំណាក់កាលក្រោយជំងឺកូវីដ-១៩**

**៣-សេចក្តីថ្លែងការណ៍រួមរបស់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៥**

បន្ទាប់មកនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ **សម្តេចក្រឡាហោម** ក៏បានអញ្ជើញជាតំណាងឱ្យកម្ពុជា ចូលរួមក្នុងពិធីប្រគល់-ទទួលតួនាទីប្រធាន **ប្តូរវេនរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៦នៅឆ្នាំ២០២២** បន្តពីប្រទេសព្រុយណេ ។ ក្នុងឱកាសទទួលតួនាទីដ៏ឧត្តុង្គឧត្តមនេះ **សម្តេចក្រឡាហោម** ក៏បានថ្លែងនូវការអបអរសាទរចំពោះប្រទេសព្រុយណេ ដែលបានបំពេញតួនាទី ជាប្រធានកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែនលើកទី២១ (21st SOMTC) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៥ (15th AMMTC) ប្រកបដោយជោគជ័យក្នុងឆ្នាំ២០២១នេះ ។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ក្រសួងមហាផ្ទៃ និងក្នុងនាមជា **ប្រធានប្តូរវេននៃកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៦ សម្តេចក្រឡាហោម** បានសម្តែងនូវសេចក្តីសោមនស្សរីករាយចំពោះតួនាទីដ៏មានសារៈសំខាន់នេះដែលមិនត្រឹមតែជាមោទនភាពសម្រាប់ព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការឆ្លុះបញ្ចាំងឱ្យឃើញនូវការចូលរួមចំណែក និងការទទួលខុសត្រូវចំពោះអនាគតរបស់សហគមន៍ ក្នុងនាមកម្ពុជាជារដ្ឋសមាជិកអាស៊ាន ។

នៅក្នុងកិច្ចប្រជុំនោះ **សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍សង្កត់ធ្ងន់អំពីភាពចាំបាច់ដែលអាស៊ានត្រូវបន្តពង្រឹងស្មារតីសាមគ្គីភាពរឹងមាំនិងការជួយគ្នាទៅវិញទៅមក ដើម្បីប្រយុទ្ធប្រឆាំងទាំងបញ្ហាជំងឺកូវីដ-១៩ និងរួមគ្នាដោះស្រាយបញ្ហាជាច្រើនទៀត ក្នុងក្របខណ្ឌនៃឧក្រិដ្ឋកម្មឆ្លងដែនជាពិសេសបទល្មើសមិនប្រពៃណីដែលកំពុងមានការកើនឡើងឥតឈប់ឈរ និងបង្កការគំរាមកំហែងដល់សន្តិសុខផ្ទៃក្នុងប្រទេស និងតំបន់ ។ ក្នុងស្មារតីនេះ **សម្តេចក្រឡាហោម** បានបង្ហាញនូវការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការបន្តខិតខំពង្រីកទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងតំបន់ឱ្យកាន់តែសកម្ម និងស៊ីជម្រៅថែមទៀត ជាមួយបណ្តារដ្ឋសមាជិកអាស៊ានលើការងារពង្រឹងការអនុវត្តច្បាប់ និងបានសម្តែងនូវក្តីសង្ឃឹមយ៉ាងមុតមាំចំពោះការបន្តគាំទ្រ និងការជួយជ្រោមជ្រែងពីសំណាក់រដ្ឋមន្ត្រីទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែននៃរដ្ឋសមាជិកអាស៊ានទាំងអស់ និងលេខាធិការដ្ឋានអាស៊ាន ដើម្បីផ្តល់លទ្ធភាពដល់កម្ពុជាបំពេញតួនាទីជា**ប្រធានកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី២២** (22nd SOMTC) **និងកិច្ចប្រជុំរដ្ឋមន្ត្រីអាស៊ានទទួលបន្ទុកឧក្រិដ្ឋកម្មឆ្លងដែនលើកទី១៦** (16th AMMTC) នៅឆ្នាំ២០២២ ប្រកបដោយប្រសិទ្ធភាព និងសម្រេចបានសមិទ្ធផលថ្មីៗបន្ថែមទៀត នៅក្រោម«**សសរស្តម្ភសន្តិសុខនយោបាយ**»ដើម្បីបម្រើដល់ឧត្តមប្រយោជន៍រួម និងបុព្វហេតុនៃសន្តិភាពវិបុលភាពសម្រាប់តំបន់អាស៊ាន ៕


៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# កិច្ចប្រជុំលើកទី១៩ (គ.ជ.អ.ប) ដើម្បីសម្រាប់ការអភិវឌ្ឍន៍តាមបែប

តាមរយៈប្រព័ន្ធវីដេអូ ZOOM សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំកិច្ចប្រជុំលើកទី ១៩ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) នៅទីស្តីការក្រសួងមហាផ្ទៃ កាលពីព្រឹកថ្ងៃទី ២១ ខែតុលា ឆ្នាំ ២០២១ ដើម្បីពិនិត្យឡើងវិញនូវវឌ្ឍនភាព និងបញ្ហាប្រឈមនានា នៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងអំឡុងឆ្នាំ ២០២០ និងក្នុងឆមាសទី ១ ឆ្នាំ ២០២១ នេះ ជាពិសេសការពិនិត្យលើសេចក្តីព្រាងឯកសារកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ ។







**៣ការពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# ពិនិត្យសេចក្តីព្រាងឯកសារគម្រោងកម្មវិធីជាតិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ





អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំនោះ **សម្តេចក្រឡាហោម** បានគូសបញ្ជាក់ថា៖ បើទោះបីប្រទេសកម្ពុជា និងបណ្តាប្រទេសនានាលើពិភពលោក បាននឹងកំពុងជួបស្ថានភាពលំបាក ដោយសារការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ក៏កម្ពុជានៅតែបន្តរួមសហការគ្នាក្នុងការរៀបចំ និងអនុវត្តកិច្ចការជាអាទិភាព និងចាំបាច់នានា ដើម្បីធានាដល់ការការពារទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកាចសាហាវនេះផង ព្រមទាំងរក្សាបាននូវនិរន្តរភាពការបំពេញការងារតាមវិស័យជំនាញនានាដោយផ្សារភ្ជាប់ជាមួយនឹងការជំរុញកិច្ចដំណើរការកំណែទម្រង់នានាផងដែរ ។

☞ ៤២



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ក្រសួងមហាផ្ទៃ កម្ពុជា និងក្រសួងសន្តិសុខ
## ការងារស្តីពីការបន្តអនុវត្តឆ្នាំ នៃ





៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# សាធារណៈ ចិន ចុះហត្ថលេខាលើផែនការ កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់





ដោយបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅល្ងាចថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ កន្លងមកនេះ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាសហប្រធាន ដឹកនាំកិច្ចប្រជុំ និងចុះហត្ថលេខាលើផែនការការងារ ស្តីពីការបន្តអនុវត្តឆ្នាំនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ជាមួយ ឯកឧត្តម **ចាវ ឃើជី** សមាជិកក្រុមប្រឹក្សារដ្ឋ និងជារដ្ឋមន្ត្រីក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាមានិតចិន តាមប្រព័ន្ធវីដេអូ ។

☞ ១១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




តមកពីទំព័រ ១០

## ក្រសួងមហាផ្ទៃ កម្ពុជា និង ក្រសួងសន្តិសុខ.....



សម្តេចក្រឡាហោម **ស ខេង** និងឯកឧត្តម **ចាវ ឃើជី** បានសម្តែងការអបអរសាទរយ៉ាងក្រៃលែងចំពោះទំនាក់ទំនងដ៏ល្អរវាងថ្នាក់ដឹកនាំកំពូលនៃប្រទេសទាំងពីរ និងកិច្ចសហប្រតិបត្តិការជិតស្និទ្ធលើគ្រប់វិស័យក្នុងភាពជា**ដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ** ដែលបានរួមចំណែកនាំមកនូវវឌ្ឍនភាព និងការអភិវឌ្ឍរីកចម្រើនសម្រាប់ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ។ **សម្តេចក្រឡាហោម** និង ឯកឧត្តម **ចាវ ឃើជី** ក៏បានថ្លែងនូវការកោតសរសើរទៅវិញទៅមកចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កងកម្លាំងអនុវត្តច្បាប់នៃភាគីទាំងពីរ ក្នុងការថែរក្សាបានយ៉ាងរឹងមាំនូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ទោះបីស្ថិតក្នុងស្ថានភាពប្រឈមដ៏ស្មុគស្មាញដែលបង្កឡើងដោយជំងឺកូវីដ-១៩ ។ ក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ភាគីទាំងពីរក៏បានកត់សម្គាល់នូវលទ្ធផល និងសមិទ្ធផលសំខាន់ៗនារយៈពេលជាង៧ឆ្នាំកន្លងមក បន្ទាប់ពីការចាប់ផ្តើមដំណើរការអនុវត្តឆ្នាំនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងក្រសួងទាំងពីរ កាលពីខែមេសា ឆ្នាំ២០១៩ ក្រោមគំនិតផ្តួចផ្តើមដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង**ឯកឧត្តម ស៊ី ជីនពីង ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន** ។ ទន្ទឹមនេះ **សម្តេចក្រឡាហោម** និង **ឯកឧត្តម ចាវ ឃើជី** ក៏បានចែករំលែក និងផ្លាស់ប្តូរទៅវិញទៅមកនូវសភាពការណ៍សន្តិសុខទូទៅ ព្រមទាំងបានកត់សម្គាល់នូវវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការប្រកបដោយផ្លែផ្កា ការជួយគាំទ្រគ្នាទៅវិញទៅមកក្នុងការប្រយុទ្ធប្រឆាំងការរាតត្បាតនៃជំងឺកូវីដ-១៩ ការជួយឧបត្ថម្ភគាំទ្រផ្នែកសម្ភារបច្ចេកទេសការងារ កសាងសមត្ថភាពកងកម្លាំង ការផ្លាស់ប្តូរទស្សនកិច្ចប្រតិភូជំនាញជាពិសេស កិច្ចសហការទប់ស្កាត់ និងបង្ក្រាបបទល្មើសឆ្លងដែនគ្រប់ប្រភេទ ។

ដោយមើលឃើញនូវសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងប្រទេសទាំងពីរ **សម្តេចក្រឡាហោម** និង**ឯកឧត្តម ចាវ ឃើជី** បានចុះហត្ថលេខាលើផែនការការងារសម្រាប់បន្តអនុវត្តឆ្នាំនៃកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ដើម្បីបន្តពង្រឹង និងពង្រីកទំនាក់



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល








ទំនង និងកិច្ចសហប្រតិបត្តិការកាន់តែសកម្មសំដៅសម្រេចបានសមិទ្ធផលថ្មីៗ

បន្ថែមទៀតបម្រើដល់ការអភិវឌ្ឍសង្គមជាតិ និងផលប្រយោជន៍ទៅវិញទៅមក

របស់ប្រជាជននៃប្រទេសទាំងពីរ ដោយក្នុងនោះ បានឯកភាពបន្តផ្តោតការយកចិត្តទុកដាក់លើការងារមួយចំនួនរួមមាន ៖

បន្តពង្រឹងកិច្ចសហប្រតិបត្តិការទប់ស្កាត់បទល្មើសឆ្លងដែនគ្រប់ប្រភេទ ជាពិសេស ឧក្រិដ្ឋកម្ម មានរង្គការចាត់តាំងល្បែងស៊ីសងអនឡាញខុសច្បាប់ អំពើឆបោក តាមប្រព័ន្ធទូរគមនាគមន៍ និងការដួញដូរគ្រឿងញៀនខុសច្បាប់ ។

បន្តកិច្ចសហការជិតស្និទ្ធ និងគាំទ្រគ្នាទៅវិញទៅមក ដើម្បីបម្រើឲ្យការប្រារព្ធនូវព្រឹត្តិការណ៍ជាតិ និងអន្តរជាតិធំៗឲ្យប្រព្រឹត្តទៅដោយជោគជ័យតាមការគ្រោងទុក ក្នុងនោះរួមមាន ការទទួលតួនាទីជាប្រធានអាស៊ាន ឆ្នាំ២០២២ ការប្រកួតកីឡារដូវរងារទីក្រុងប៉េកាំងឆ្នាំ២០២២ និងការរៀបចំព្រឹត្តិការណ៍កីឡា SEA Games លើកទី៣២ ឆ្នាំ២០២៣ ព្រមទាំងព្រឹត្តិការណ៍ជាតិសំខាន់ៗដ៏ទៃទៀត ដែលប្រារព្ធធ្វើនៅព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតចិន ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# ឆមាសទី ១ ឆ្នាំ ២០២១



នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ កន្លងមកនេះ តាមរយៈប្រព័ន្ធវីដេអូ( ZOOM ) សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក( គ.សច.គ )បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំបូកសរុបការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកឆមាសទី១ និងលើកទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ របស់ គ.ស.ច.គ ។



លោកជំទាវ **មីន មាណវី** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន គ.ស.ច.គ. បានបញ្ជាក់ឱ្យដឹងអំពីលទ្ធផលការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២១ថា៖ តាមរយៈការរឹតបន្តឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក សមត្ថកិច្ចបានពិន័យយានយន្តល្មើសច្បាប់ សរុបចំនួន ១០៥.៩៩៥គ្រឿង និងក្នុងចំណោមអ្នកស្លាប់ជាអ្នកជិះម៉ូតូចំនួន ៧៨%( ៥៥៥/៧០៩នាក់) មានអ្នកមិនពាក់មួកសុវត្ថិភាពចំនួន៦៩%( ៣៨៥/៥៥៥នាក់) ។ ទន្ទឹមនេះគ្រោះថ្នាក់បានកើតឡើងច្រើននៅរាជធានីភ្នំពេញ ៣៤០



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

# គ្រោះថ្នាក់ចរាចរណ៍ថយចុះ ៣៥៨លើក អ្នកស្លាប់ថយចុះ ១៥២នាក់ និងអ្នករបួសថយចុះ ៦៥៧នាក់

លើក ខេត្តកណ្ដាល ៨៦លើក និងខេត្តស្វាយរៀង ៧៧លើក ។ ក្នុងនោះរួមមាន ៖ ទោចក្រយានយន្ត ត្រីចក្រយានយន្ត ចំនួន ៧៧.៧៩៤គ្រឿង ស្មើ៧៣% ។ ដោយឡែក រថយន្ត ចំនួន ២៨.២០១គ្រឿង ដោយក្នុងនោះមានរថយន្តធុនធ្ងន់៦.៤៣១គ្រឿង។







លោកជំទាវ រដ្ឋលេខាធិការ បានបញ្ជាក់ទៀតថា៖ ក្នុងឆមាសទី១ ឆ្នាំ២០២១ គ្រោះថ្នាក់ចរាចរណ៍កើតឡើង សរុប១.២៦១លើក (ឃប់៥៤%) បណ្ដាលឱ្យស្លាប់ ៧០៩នាក់ និងរបួស ១.៧៩២នាក់ (ធ្ងន់ ១.០៨៦នាក់)។មូលហេតុបង្កគ្រោះថ្នាក់រួមមាន ល្មើសល្បឿន៣៤% បើកបរមិនគោរពសិទ្ធិ២៣% មិនប្រកាន់ស្ដាំ១៦% វ៉ាជែង៨% បត់៩% កត្តាយានយន្ត៣% ស្រវឹង៣% និងងងុយ១% ។ បើគិតក្នុងឆមាសទី១ ឆ្នាំ២០២១ ធៀបទៅនឹងឆមាសទី១ ឆ្នាំ២០២០ **គ្រោះថ្នាក់ចរាចរណ៍ថយចុះ ៣៥៨លើក ស្មើ២២% (១២៦១/១៦១៩លើក) ចំនួនអ្នកស្លាប់ថយចុះ ១៥២នាក់** ស្មើ១៨% (៧០៩/ ៨៦១នាក់) និង**ចំនួនអ្នករបួសថយចុះ ៦៥៧នាក់** ស្មើ ២៧% (១៧៩២/២៤៤៩នាក់)។

ឯកឧត្តម **តូច ចាន់កុសល** រដ្ឋលេខាធិការប្រចាំការក្រសួងសាធារណការ និងដឹកជញ្ជូន តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និងជាអនុប្រធានអចិន្ត្រៃយ៍គ.ស.ច.គ. បានឱ្យដឹងថា៖ យានដ្ឋានដួសជុល និងយានដ្ឋានកែច្នៃដំឡើងយានយន្ត គិតត្រឹម ខែកក្កដា ឆ្នាំ២០២១ មាន ចំនួន ៤.៥៣២ កន្លែង (មានច្បាប់ ៣.៩៧១កន្លែង អត់ច្បាប់ ៣៨០កន្លែង) បានបិទយានដ្ឋាន សរុប ចំនួន ១៨១កន្លែង ។

ដោយឡែកទិសដៅសំខាន់ៗសម្រាប់អនុវត្តក្នុងឆមាសទី២ ឆ្នាំ២០២១ មានជាអាទិ៍៖ បន្តយុទ្ធនាការអប់រំផ្សព្វផ្សាយ

☞ ៤៧



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# សម្ដេចក្រឡាហោម អនុញ្ញាតឲ្យ អមស្ថានទូត វៀតណាម ប្រចាំនៅកម្ពុជា





នារសៀលថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០២១ នៅទីស្ដីការក្រសួងមហាផ្ទៃ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអនុញ្ញាតឱ្យ លោកឧត្តមសេនីយ៍ត្រី **ង្វៀន ហាយសឹន** ប្រធានស្ថានតំណាងក្រសួងនគរបាលអមស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា និងសហការីចូលជួបសម្ដែងការគួរសម និងជម្រាបលាក្នុងឱកាសដែលលោកបញ្ចប់បេសកកម្មអាណត្តិការងារនៅព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងជំនួបនោះ **សម្ដេចក្រឡាហោម** បានសម្ដែងការកោតសរសើរ ព្រមទាំងវាយតម្លៃខ្ពស់ចំពោះសកម្មភាពការងាររបស់លោកឧត្តមសេនីយ៍ត្រី **ង្វៀន ហាយសឹន** ដែលបានខិតខំបំពេញភារកិច្ចយ៉ាងសកម្មក្នុងតួនាទីជាប្រធានស្ថានតំណាងក្រសួងនគរបាលអមស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា ក្នុងអាណត្តិការងាររបស់ខ្លួន ។



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ប្រធានស្ថានតំណាងក្រសួងនគរបាល ចូលជួបសម្តែងការគួរសម និងជម្រាបលា

ហើយតាមរយៈកិច្ចសហប្រតិបត្តិការដ៏ល្អរវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងនគរបាលវៀតណាមនាពេលកន្លងមក **សម្តេចក្រឡាហោម** នៅតែសង្ឃឹមថាអ្នកដែលមកបន្តអាណត្តិការងារនាពេលបន្ទាប់នៅតែបន្តពង្រឹងកិច្ចសហប្រតិបត្តិការការងារដែលជាសមិទ្ធផលរបស់ក្រសួងទាំងពីរធ្លាប់មានកន្លងមក ព្រមទាំងពង្រីកឱ្យកាន់តែមានវឌ្ឍនភាពល្អប្រសើរថែមទៀត ។

មានមតិឆ្លើយតបវិញ លោកឧត្តមសេនីយ៍ត្រី ប្រធានស្ថានតំណាងក្រសួងនគរបាល អមស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា ក៏បានជម្រាបជូន **សម្តេចក្រឡាហោម** ជ្រាបថា៖ លោកពិតជាមានក្តីរីករាយ ព្រមទាំងមានមោទនភាពដែលត្រូវបានតែងតាំងជាប្រធានស្ថានតំណាងក្រសួងនគរបាលអមស្ថានទូតវៀតណាមប្រចាំនៅកម្ពុជា នាពេលកន្លងមក ហើយលោកក៏សូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងក្រសួងទាំងពីរក្នុងអាណត្តិបំពេញការងាររយៈពេល៣ឆ្នាំកន្លងមកនេះ ។

ហើយក្រោយពេលបញ្ចប់អាណត្តិការងារ លោកនឹងបន្តដើរតួនាទីក្នុងការផ្សារភ្ជាប់ទំនាក់ទំនងល្អលើវិស័យអប់រំរវាងសកលវិទ្យាល័យ **ជាតិបាត់ដំបង** ជាមួយសកលវិទ្យាល័យ**កាន់ធើនៃប្រទេសវៀតណាម** សំដៅធ្វើយ៉ាងណារួមចំណែកលើកកម្ពស់លើវិស័យអប់រំនៃប្រទេសទាំងពីរ ។

ជាចុងក្រោយ **សម្តេចក្រឡាហោម** ក៏បានសម្តែងនូវការអរគុណចំពោះ លោកឧត្តមសេនីយ៍ត្រី **ង្វៀន ហាយសឺន** ក្នុងការខិតខំប្រឹងប្រែងផ្សារភ្ជាប់ទំនាក់ទំនងរវាងសកលវិទ្យាល័យជាតិបាត់ដំបងជាមួយសកលវិទ្យាល័យ **កាន់ធើន ប្រទេសវៀតណាម** ។ ទន្ទឹមនេះ **សម្តេចក្រឡាហោម** ក៏បានមានប្រសាសន៍បញ្ជាក់ទៀតថា៖ **សម្តេច** ក៏ជាអ្នកផ្តួចផ្តើមកសាងនូវសកលវិទ្យាល័យ **ជាតិបាត់ដំបង** សកលវិទ្យាល័យ **ជា ស៊ីម កំចាយមារ** និងសកលវិទ្យាល័យ **ត្បូងឃ្មុំ** ផងដែរ ដូច្នេះសម្តេចសង្ឃឹមថាកិច្ចសហប្រតិបត្តិការជាមួយគ្នា លើវិស័យអប់រំនាពេលខាងមុខ និងរួមចំណែកជួយសម្រួលដល់ការលើកកម្ពស់នូវវិស័យអប់រំនៅកម្ពុជា កាន់តែល្អប្រសើរមួយកម្រិតថែមទៀត ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# អភិបាលខេត្តចំនួន៧រូប ត្រូវបានផ្ទេរភារកិច្ច

ឯកឧត្តម **ស្វាយ សំអ៊ាង** បាននូវសក្តិឧត្តមមន្រ្តីថ្នាក់លេខ១ ពីអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរីទៅជាអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២១/៧០៤ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។



ឯកឧត្តម **ថង សាវុន** បាននូវសក្តិឧត្តមមន្រ្តីថ្នាក់លេខ១ ពីអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ទៅជាអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២១/៧០៥ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។



ឯកឧត្តម **ញ៉ែម សំអឿន** បាននូវសក្តិឧត្តមមន្រ្តីថ្នាក់លេខ៤ ជាអភិបាលនៃគណៈអភិបាលខេត្តរតនគិរី តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២១/៧០៦ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។





៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




ឯកឧត្តម **ម៉ៅ ធនិន** ឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ១១ ពីអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ទៅជាអភិបាលនៃគណៈអភិបាលខេត្តកំពត តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២១/៧០៧ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។



ឯកឧត្តម **ជាវ តាយ** ឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ១១ ពីអភិបាលនៃគណៈអភិបាលខេត្តកំពត ទៅជាអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២១/៧០៨ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។



ឯកឧត្តម **សុខ លូ** ឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ១១ ពីអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ទៅជាអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២១/៧០៩ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។



ឯកឧត្តម **ខួន រតនៈ** ឋានន្តរស័ក្តិឧត្តមមន្ត្រីថ្នាក់លេខ១២ ពីអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ទៅជាអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ តាមព្រះរាជក្រឹត្យលេខ នស/រកត/០៩២១/៧១០ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឯកឧត្តម ម៉ៅ ធនិន អតីតអភិបាល
# និងប្រកាសចូលកាន់មុខតំណែង





៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:10 AM




# ខេត្តពោធិសាត់ ត្រូវបានផ្ទេរភារកិច្ច ជាអភិបាលខេត្តកំពត


ឯកឧត្តម ម៉ៅ ធនិន អភិបាលនៃគណៈអភិបាលខេត្តកំពត

នារសៀលថ្ងៃទី១៣ ខែតុលា ឆ្នាំ ២០២១ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសចូលកាន់មុខតំណែង ឯកឧត្តម **ម៉ៅ ធនិន** ជាអភិបាលនៃគណៈអភិបាលខេត្តកំពត ជំនួសឯកឧត្តម **ជាវ តាយ** ដែលត្រូវបានព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានសព្វព្រះរាជហឫទ័យដ៏ខ្ពង់ខ្ពស់បំផុតផ្ទេរភារកិច្ច ជាអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ។

ឯកឧត្តម **ជាវ តាយ** អភិបាលនៃគណៈអភិបាលខេត្តកំពត ដែលត្រៀមអញ្ជើញទៅកាន់មុខតំណែង ជាអភិបាលនៃគណៈអភិបាលខេត្តខេត្តពោធិ៍សាត់ បានបញ្ជាក់ឱ្យដឹងថា៖ ខេត្តកំពត គឺជាខេត្តមួយ ដែលមានរំណោយផលល្អពីធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍលើវិស័យកសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម និង

☞ ៦៣



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/tavz/



# កិច្ចប្រជុំលើកទី ១១ ស្តីពីកិច្ចសហប្រតិបត្តិការ និង






កិច្ចប្រជុំលើកទី ១១ស្តីពីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម បានបញ្ចប់នាព្រឹកថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០២១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និង ឯកឧត្តម **ផាម ប៊ីញមីញ** ឧបនាយករដ្ឋមន្ត្រីប្រចាំការនៃសាធារណរដ្ឋសង្គមនិយមវៀតណាម តាម ប្រព័ន្ធវីដេអូ។

ក្នុងកិច្ចប្រជុំនេះភាគីទាំងពីរបានសង្កត់ធ្ងន់ពីសារសំខាន់នៃការបន្តថែរក្សាទំនាក់ទំនងជាមិត្តភាព និងកិច្ចសហប្រតិបត្តិការបណ្តាខេត្តជាប់ព្រំដែនកម្ពុជា- វៀតណាម ក៏ដូចជាពង្រីងពង្រឹកចំណងទំនាក់ទំនងក្នុងលក្ខណៈ « **ភាពជាអ្នកជិតខាងល្អ មិត្តភាពជាប្រពៃណី កិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយ និងថេររឹងមាំយូរអង្វែងរវាងកម្ពុជា និងវៀតណាម** »។

ភាគីទាំងពីរបានពិភាក្សាអំពីរបៀបវារៈសំខាន់ៗ ដូចជាលទ្ធផលនៃ



**៣ការពារ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:10 AM




# ការអភិវឌ្ឍន៍បណ្តាខេត្តជាប់ព្រំដែន កម្ពុជា- វៀតណាម





កិច្ចសហប្រតិបត្តិការរវាងប្រទេស និងប្រទេស និងរវាងខេត្តជាប់ព្រំដែន តាមរយៈការរៀបចំឱ្យមានជំនួបប្រាស្រ័យ សន្ទនាតាមទូរសព្ទ ពិគ្រោះពិភាក្សាតាម

ប្រព័ន្ធវីដេអូ ដោយបានលើកទឹកចិត្ត បង្កើនការវិនិយោគ បន្តឧបត្ថម្ភគាំទ្រ ដល់បណ្តាខេត្តជាប់ព្រំដែន និងបង្កើន កិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពបន្ថែមទៀត សំដៅដោះស្រាយឱ្យបានទាន់ពេលវេលានូវបញ្ហាប្រឈម និងសំណូមពរចាំបាច់ជាក់ស្តែងនានា ។

ភាគីទាំងពីរបានវាយតម្លៃខ្ពស់អំពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការក្នុងវិស័យសន្តិសុខ ការពារជាតិ ដើម្បីថែរក្សាឱ្យបានរឹងមាំនូវសន្តិភាព ស្ថិរភាព សន្តិសុខរបស់ប្រទេសនីមួយៗ ។ ជាមួយគ្នានេះក៏បានអបអរសាទរការប្រារព្ធពិធីសម្ពោធដាក់ឱ្យដំណើរការជាបណ្តោះអាសន្នច្រកទ្វារព្រំដែនអន្តរជាតិ **មុនជ័យ-តឹនណាម** ក្នុងកម្រិតថ្នាក់ខេត្តរវាងខេត្តព្រៃវែង និងខេត្តតៃនិញ និងបានឯកភាពរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ច្រកទ្វារអន្តរជាតិនេះ

៤១



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/tavz/



# កិច្ចប្រជុំ ពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី និងក្រមសីលធម៌ រវាងច្រកទេសន្តរប្រវេសន៍

នាព្រឹកថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២១ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ ជ ប ជ) ដោយមានកិច្ចសហការជាមួយអង្គការ IOM បានរៀបចំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ ដើម្បីពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការជ្រើសរើសពលករប្រកបដោយយុត្តិធម៌និងក្រមសីលធម៌រវាងច្រកទេសន្តរប្រវេសន៍ការងារពីប្រទេសកម្ពុជាទៅប្រទេសថៃ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ។

គួរបញ្ជាក់ថា ៖ កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិនេះជាវេទិកាមួយសម្រាប់តំណាងរដ្ឋាភិបាលនៃគូរអភិវឌ្ឍន៍ និយោជក អ្នកជ្រើសរើសការងារ និងសមាគមរបស់ខ្លួន សង្គមស៊ីវិល និង








៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



# ការជ្រើសរើសពលករប្រកបដោយយុត្តិធម៌
# ការងារពីប្រទេស កម្ពុជា ទៅប្រទេស ថៃ



អង្គការពាក់ព័ន្ធការងារពលករ និងកម្មករ ដើម្បីចូលរួមកិច្ចសន្ទនាស្តីពីការជំរុញការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងការប្តេជ្ញាចិត្តរបស់វិស័យឯកជនទាក់ទងនឹងការជ្រើសរើសពលករចំណាកស្រុកកម្ពុជា ។

កម្មវិធីនេះធ្វើឡើងក្នុងគោលបំណង៖ **១**- បង្កើនប្រសិទ្ធភាពការវិភាគលើឯកសារគោលនយោបាយរបស់អង្គការ IOM លើការវិភាគប្រៀបធៀបនៃក្របខណ្ឌច្បាប់ជាតិ និងស្តង់ដារអន្តរជាតិនៅកម្ពុជា ទៅកាន់ច្រករបៀងចំណាកស្រុកប្រទេសថៃ ។ **២**- ពិភាក្សាអំពីអនុសាសន៍ដើម្បីលើកកម្ពស់ការជ្រើសរើសបុគ្គលិកដោយយុត្តិធម៌ និងសីលធម៌សម្រាប់ច្រករបៀង ចំណាកស្រុកពលករកម្ពុជាទៅប្រទេសថៃ ។ **៣**-លើកសំណើរជាក់ស្តែង ដើម្បីលើកកម្ពស់ការជ្រើសរើសដោយយុត្តិធម៌ និងសីលធម៌សម្រាប់ច្រករបៀងចំណាកស្រុកពលករកម្ពុជាទៅប្រទេសថៃ ។**៤**-រៀបចំភាគីពាក់ព័ន្ធរបស់កម្ពុជា ដើម្បីចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីនាពេលខាងមុខរវាងកម្ពុជានិងថៃ ស្តីពីការជំរុញកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់ការជ្រើសរើសបុគ្គលិកប្រកបដោយយុត្តិធម៌ និងសីលធម៌ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:10 AM

# ពិធី ប្រគល់-ទទួល សម្ភារបរិក្ខា ប្រើប្រាស់ឆ្នាំ ២០២១






ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **ម៉ៅ ច៊ុនណារិន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការលទ្ធកម្ម (គល) នាព្រឹកថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០២១ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រគល់-ទទួលឯកសារជំនាញគ្រប់ប្រភេទប្រើប្រាស់ឆ្នាំ ២០២១ ជូនអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអគ្គនាយកដ្ឋាន







៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/tavz/ Page 28 of 68

# បច្ចេកទេសមិនមែនព័ត៌មានវិទ្យា ជូនអង្គភាពចំណុះ ក្រសួងមហាផ្ទៃ













ភស្តុភារ និងហិរញ្ញវត្ថុ ព្រមទាំងបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យា ប្រើប្រាស់ឆ្នាំ ២០២១ ជូនអង្គភាពចំណុះ ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ ដែលពិធីនេះធ្វើឡើងនៅនាយកដ្ឋាន ភស្តុភារនិងសម្ភារបច្ចេកទេស (ព្រែកប្រា) ។

ដោយផ្អែកតាមកិច្ចសន្យាលេខ ៦១៦ សហវ-អលសា ចុះថ្ងៃទី ២៧ ខែ សីហា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការ ទិញ-លក់សម្ភារ និងបរិក្ខាបច្ចេកទេសមិនមែនព័ត៌មានវិទ្យា ប្រើប្រាស់ឆ្នាំ ២០២១ ជូនអង្គភាពចំណុះ ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ និងយោងតាមសំណើរបស់ក្រុមហ៊ុន **ជីវ ឡេង** ពាណិជ្ជ **ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត រដ្ឋលេខាធិការ** និងជាអនុប្រធាន (គល) បានមានប្រសាសន៍ក្រើនរំលឹកដល់គណៈកម្មាធិការប្រគល់-ទទួលឲ្យយកចិត្តទុកដាក់ធ្វើការត្រួតពិនិត្យឲ្យបានហ្មត់ចត់ ត្រឹមត្រូវ នូវបរិមាណ គុណភាព ប្រភពផលិត និងលក្ខណៈបច្ចេកទេសដូចមាន ចែងក្នុង ប្រការ៧នៃកិច្ចសន្យា ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# កិច្ចប្រជុំសប្តាហ៍បច្ចេកវិទ្យាអន្តរជាតិ សិង្ហបុរី លើកទី ៦

## ( SICW ) ឆ្នាំ ២០២១ និងសន្និសីទថ្នាក់រដ្ឋមន្ត្រី អាស៊ាន ផ្ដោតលើប្រធានបទ

## « រៀនរស់ជាមួយ កូវីដ-១៩»

នៅទីស្តីការក្រសួងមហាផ្ទៃ នាយប់ថ្ងៃទី៥ ខែតុលា ឆ្នាំ២០២១ ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញដឹកនាំគណៈប្រតិភូក្រសួងមហាផ្ទៃ ចូលរួមកិច្ចប្រជុំ **សប្តាហ៍បច្ចេកវិទ្យាអន្តរជាតិសិង្ហបុរី លើកទី៦** (SICW) ឆ្នាំ២០២១ និង **សន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ានស្តីពីសន្តិសុខបច្ចេកវិទ្យា** និងផ្តោតសំខាន់លើប្រធានបទ «**រៀនរស់ជាមួយកូវីដ-១៩**» រៀបចំឡើងមានរយៈពេល៥ថ្ងៃ គឺចាប់ពី






៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល













ថ្ងៃទី០៤ ដល់ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២១ ដែលមានប្រទេសសិង្ហបុរី ធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំតាមរយៈប្រព័ន្ធវីដេអូសន្និសីទ ដោយមានតំណាងមកពីអង្គភាពពាក់ព័ន្ធចំណុះក្រសួងមហាផ្ទៃ ចំនួន០៨ អង្គភាពចូលរួម ។

គួរជម្រាបជូនផងដែរថា ៖ កម្ពុជាមានក្រសួងចំនួន០២ ដែលត្រូវបានភាគីជាម្ចាស់ផ្ទះប្រទេសសិង្ហបុរី អញ្ជើញឲ្យចូលរួមកិច្ចប្រជុំសប្តាហ៍បច្ចេកវិទ្យាអន្តរជាតិសិង្ហបុរី លើកទី៦ (SICW) ឆ្នាំ២០២១ និងសន្និសីទថ្នាក់រដ្ឋមន្ត្រីអាស៊ាន នេះរួមមាន៖ ក្រសួងមហាផ្ទៃ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ៕


៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# អគារទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិ ប្រគល់–ទទួល ជាផ្លូវការ



នាព្រឹកថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ កន្លងមកនេះ នៅអគារទីស្នាក់ការ ច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត (កម្ពុជា-ថៃ) ខេត្តបន្ទាយមានជ័យ ឯកឧត្តម នាយឧត្តមសេនីយ៍ **សេខ យូអ៊ិន** អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ណ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **សក់ សេដ្ឋា** រដ្ឋលេខាធិការប្រចាំការក្រសួងមហាផ្ទៃ បានអញ្ជើញ



**៣ការពារ ៖** -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




# ប៉ោយប៉ែត ត្រូវបានរៀបចំពិធី
## បន្ទាប់ពីសាងសង់រួចរាល់ជាស្ថាពរ





ចូលរួមក្នុងពិធីប្រគល់-ទទួលអគារទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត (កម្ពុជា-ថៃ) ។

អគារទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត (កម្ពុជា-ថៃ) ខេត្តបន្ទាយមានជ័យ មានទីតាំងស្ថិតនៅលើផ្ទៃដីទំហំ៨៦១៨ម៉ែត្រការ៉េ ក្នុងនោះរួមមាន៖ អគារបំពេញបែបបទច្រកចេញ-ចូលទំហំ ៣៥,៥០ម × ៥៦,៣៩ម ដែលមានកម្ពស់ ៣ជាន់( ជាន់ផ្ទាល់ដី ជាន់ទី១ ជាន់ទី២) អំពីបង្គោលបេតុង ជញ្ជាំងឥដ្ឋ ដំបូលប្រក់ក្បឿងស្រកាលេញ ភ្លើងបុស្សក ចំនួន០៥ និងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ។

☞ ៤៨



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# កិច្ចប្រជុំពិនិត្យ និងពិគ្រោះយោបល់លើសេចក្តីព្រាង
## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ផ្នែកចំណុះ
# ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ







នៅសាលប្រជុំអគ្គនាយកដ្ឋានអន្តោប្រវេសន៍ កាលពីព្រឹកថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២១ កន្លងមកនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានអញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យ និងពិគ្រោះយោបល់លើសេចក្តីព្រាង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ផ្នែកចំណុះប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិ ផ្លូវគោក ទឹក និងអាកាស ។

មានប្រសាសន៍ក្នុងកិច្ចប្រជុំនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** បានបញ្ជាក់ថា៖ កន្លងមក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ធ្លាប់មានបទដ្ឋានកំណត់តួនាទីភារកិច្ចរបស់ការិយាល័យ និងផ្នែកចំណុះនាយកដ្ឋានរួចហើយ ក៏ប៉ុន្តែតួនាទីភារកិច្ចសម្រាប់កំណត់ទៅដល់ប៉ុស្តិ៍ច្រកទ្វារនីមួយៗនៅមិនទាន់មាន



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល








នៅឡើយទេ ដូច្នេះហើយបានជាពេលនេះយើងត្រូវបង្កើតឲ្យមានសេចក្តីសម្រេច ស្តីពី តួនាទីភារកិច្ច ផ្នែកចំណុះប៉ុស្តិ៍នគរបាល ច្រកទ្វារព្រំដែនអន្តរជាតិ ដោយសារតែលក្ខណៈពិសេសរបស់ប៉ុស្តិ៍នីមួយៗ គឺ មិនដូចគ្នាទេ ។

ពាក់ព័ន្ធបញ្ហានេះ ឯកឧត្តមនាយឧត្តមសេនីយ៍ អគ្គនាយក ក៏បានស្នើឲ្យអគ្គនាយករងទទួលបន្ទុក ព្រមទាំងប្រធាន អនុប្រធាននាយកដ្ឋាន និងក្រុមការងារជួយពិនិត្យសេចក្តីព្រាង សេចក្តីសម្រេចនេះលើទម្រង់បែបបទ ឯកសារនិងជួយកែសម្រួលពាក្យពេចន៍ ខ្លឹមសារឲ្យមានលក្ខណៈសមស្របទៅតាមបទដ្ឋានគតិយុត្ត ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# អគ្គនាយកដ្ឋានពន្ធនាគារ ទទួលរថយន្ត សង្គ្រោះបន្ទាន់ពីក្រុមហ៊ុន Postegy Group Holdings

ពិធីប្រគល់-ទទួលរថយន្តសង្គ្រោះបន្ទាន់ សម្ភារបរិក្ខារពេទ្យ និងសម្ភារការពារជំងឺកូវីដ-១៩មួយចំនួនទៀតពីក្រុមហ៊ុន Postegy Group Holdings (Hong Kong) Inc. និងសប្បុរសជន ជូនអគ្គនាយកដ្ឋានពន្ធនាគារ ក្រោមអធិបតីភាពឯកឧត្តម ឧត្តមអគ្គានុរក្សថ្នាក់លេខ១ **ឆែម សាវុធ** អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ ត្រូវបានរៀបចំកាលពីព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២១ នៅសាលប្រជុំមណ្ឌលអប់រំកែប្រែទី១ ព្រៃស ដែលមានទីតាំងស្ថិតនៅសង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ ។







៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



រថយន្តសង្គ្រោះបន្ទាន់នេះ ត្រូវបាន ប្រគល់ជូន មណ្ឌលអប់រំកែប្រែទី៣ ដែល ជាជំនួយឧបត្ថម្ភពី លោក **ឡូ ប៊ីន** នាយកប្រតិបត្តិនៃក្រុមហ៊ុន Postegy Group Holdings (Hong Kong) Inc. និងលោក **តាំង សំណាង** ប្រធានការិយាល័យធៀនភីង និងសប្បុរសជន ។






បានមកពីសំណេះសំណាលក្នុងពិធីប្រគល់-ទទួលនោះ ឯកឧត្តម ឧត្តមសេនីយ៍ត្រី ... អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមហ៊ុន Postegy Group Holdings (Hong Kong) Inc.និងសប្បុរសជនទាំងអស់ ដែលមានទឹកចិត្តសប្បុរសធម៌ប្រគល់រថយន្តសង្គ្រោះបន្ទាន់សម្ភារបរិក្ខារពេទ្យ និងសម្ភារការពារជំងឺកូវីដ-១៩ មួយចំនួនទៀត ជូនដល់អគ្គនាយកដ្ឋានពន្ធនាគារក្រសួងមហាផ្ទៃ ស្របពេលដែលពិភពលោក ក៏ដូចជាប្រទេសកម្ពុជា កំពុងប្រយុទ្ធប្រឆាំង និងការឆ្លងរាលដាលនៃជម្ងឺកូវីដ ១៩ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឯកឧត្តម នាយឧត្តមសេនីយ៍ ហ៊ី សាគុណា អញ្ជើញពិនិត្យសភាពការណ៍តាមខ្សែបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់ការ ឆ្លងដែនខុសច្បាប់





នៅព្រឹកថ្ងៃទី២១-២២ ខែកញ្ញា ឆ្នាំ២០២១ កន្លងទៅនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ **ហ៊ី សាគុណា** អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែនតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គស្នងការនគរបាលជាតិ និងសហការី បានអញ្ជើញចុះត្រួតពិនិត្យសភាពការណ៍ និងពង្រឹងកម្លាំងឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែន ដើម្បីពង្រឹងការងារទប់ស្កាត់ការលួចចេញ-ចូលឆ្លងកាត់ព្រំដែនខុសច្បាប់របស់ពលករខ្មែរមកពីប្រទេសថៃ ។

ក្នុងដំណើរចុះបំពេញបេសកកម្មនេះ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការរង បានអញ្ជើញទៅពិនិត្យសកម្មភាពការងាររបស់បងប្អូនកងកម្លាំងតាមគោលដៅប្រចាំការតូចៗ និងត្រួតពិនិត្យភូមិសាស្ត្រតាមខ្សែបន្ទាត់ព្រំដែន ចាប់ពីភូមិសាស្ត្រប៉ុស្តិ៍ព្រំដែនគីឡូ៩ រហូតដល់ចំណុចច្រកទ្វារ



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







ព្រំដែនអន្តរជាតិ គីឡូ១៣ ក្នុងភូមិសាស្ត្រ ប៉ុស្តិ៍ព្រំដែន គីឡូ១៣ ។

គ្រប់ទីកន្លែងដែលបានអញ្ជើញដល់ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គស្នងការរងបានក្រើនរំលឹកបងប្អូនកងកម្លាំងដែលឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែន ឲ្យយកចិត្តទុកដាក់ថែមទៀត ក្នុងការលើកកំពស់ស្មារតីទទួលខុសត្រូវអនុវត្តន៍ភារកិច្ចរបស់ខ្លួនឲ្យបានម៉ឺងម៉ាត់ក្នុងការគ្រប់គ្រងសកម្មភាពឆ្លងកាត់ព្រំដែន ដោយសហការបង្រ្កាបមុខសញ្ញានាំពលករខ្មែរចេញ-ចូលឆ្លងកាត់ព្រំដែនខុសច្បាប់ និងត្រូវមានឆន្ទៈម៉ោះមុតប្តេជ្ញាចូលរួមទប់ស្កាត់និងកាត់ផ្តាច់ការឆ្លងរីករាលដាលនៃជម្ងឺកូវីត១៩ បម្លែងថ្មី**ដែលតា** ជាពិសេសពង្រឹងការអនុវត្តវិធានការសុខាភិបាល ៣កុំ៣ការពារឲ្យបានជាប់ជាប្រចាំ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



# ឯកឧត្តម នាយឧត្តមសេនីយ៍ កែវ វណ្ណថន ទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូតំណាងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាមានិតចិន





៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល








នាព្រឹកថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០២១ ឯកឧត្តម នាយឧត្តមសេនីយ៍ **កែវ វណ្ណថន** អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម នាយឧត្តមសេនីយ៍ **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូតំណាងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាមានិតចិន ដែលដឹកនាំដោយ លោក Wu JianMin អនុប្រធាននាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានតំណាងភាគីចិន នៃការិយាល័យសម្របសម្រួលអនុវត្តច្បាប់ចិន និងកម្ពុជា ។

នៅក្នុងជំនួបខាងលើ ភាគីទាំងពីរបានវាយតម្លៃខ្ពស់ ចំពោះកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់រវាងក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈនៃសាធារណរដ្ឋប្រជាមានិតចិន នាពេលកន្លងមក និងបានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការស្របតាមគោលការណ៍ និងកិច្ចសហប្រតិបត្តិការរវាងក្រសួងទាំងពីរ ។

ជាមួយគ្នានេះ លោក Wu JianMin តំណាងក្រសួងសន្តិសុខសាធារណចិន បានថ្លែងអំណរគុណអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដែលតែងតែខិតខំសម្របសម្រួល និងផ្តល់កិច្ចសហការល្អក្នុងកិច្ចសហប្រតិបត្តិការបង្ការ និងទប់ស្កាត់បទល្មើសឆ្លងដែន នាពេលកន្លងមក ។

មានមតិឆ្លើយតបវិញ ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ក៏បានថ្លែងអំណរគុណចំពោះភាគីចិន ដែលតែងតែជួយឧបត្ថម្ភគាំទ្រទាំងសម្ភារបច្ចេកទេសព្រមទាំងផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលអន្តោប្រវេសន៍កម្ពុជា នាពេលកន្លងមកដែលបង្ហាញពីកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ រវាងប្រទេសទាំងពីរ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# កិច្ចប្រជុំរៀបចំផែនការមេ សម្រាប់ការអភិវឌ្ឍន៍ ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រង អន្តោប្រវេសន៍



ឧត្តមសេនីយ៍ឯក សុខ វាសនា អគ្គនាយករង និងជាប្រធាននាយកដ្ឋានជនបរទេស
មិនមែនអន្តោប្រវេសន្ត និងបច្ចេកវិទ្យា នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍









នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ កន្លងមកនេះ នៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានបើកកិច្ចប្រជុំរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងអន្តោប្រវេសន៍ ដោយមានការអញ្ជើញចូលរួមពីសំណាក់ ឧត្តមសេនីយ៍ឯក សុខ វាសនា អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងជាប្រធាននាយកដ្ឋានជនបរទេសមិនមែនអន្តោប្រវេសន្ត និងបច្ចេកវិទ្យា និងជាប្រធានក្រុមការងារចំពោះកិច្ចរៀបចំផែនការមេសម្រាប់ការអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងអន្តោប្រវេសន៍ ព្រមទាំងមានការចូលរួមពីលោក លោកស្រីអនុប្រធាននាយកដ្ឋានពាក់ព័ន្ធជាច្រើនរូបទៀត ។

មានមតិនៅក្នុងកិច្ចប្រជុំនេះ ឧត្តមសេនីយ៍ឯក អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានគូសបញ្ជាក់ពីអន្តោប្រវេសន៍មួយដែលមានសមត្ថភាពគ្រប់គ្រាន់ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់



៣គារពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល







ក្នុងការគ្រប់គ្រងអន្តោប្រវេសន៍ផង និងការងារសន្តិសុខរបស់ប្រទេសជាតិផង ដោយផ្អែកតាមផែនការយុទ្ធសាស្ត្ររយៈពេល០៥ឆ្នាំ (២០១៩-២០២៤) របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ តាមការសម្រេចរបស់ថ្នាក់ដឹកនាំក្រសួង និងរាជរដ្ឋាភិបាលកម្ពុជា ។

ដោយឡែក ការរៀបចំផែនការសកម្មភាពលំអិត ការរៀបចំសមាសភាពក្រុមការងារឲ្យបំពេញភារកិច្ចតាមផ្នែក និងជំនាញនីមួយៗ ព្រមទាំងតម្រូវការចាំបាច់ដទៃទៀត នឹងត្រូវលើកយកមកពិភាក្សាបន្តឲ្យបានល្អិតល្អន់នាកិច្ចប្រជុំក្រោយៗទៀត ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

តមកពីទំព័រ ២២

## កិច្ចប្រជុំលើកទី ១១ ស្តីពី កិច្ចសហប្រតិបត្តិ.....

ជាមួយនឹងបណ្តាតំបន់ដែលមានសក្តានុពលសេដ្ឋកិច្ចនៅប្រទេសនីមួយៗ ។

ភាគីទាំងពីរក៏បានពិភាក្សាអំពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការដឹកជញ្ជូនផ្លូវគោកឆ្លងកាត់ព្រំដែន ការទិញលក់អគ្គិសនី ការប្រើប្រាស់ទឹក និងការផ្តល់សេវាសុខាភិបាល ។ ភាគីទាំងពីរឯកភាពដំណើរការអនុវត្តឱ្យមានប្រសិទ្ធភាព **«កិច្ចព្រមព្រៀងស្តីពីវិស័យចត្តាឡីសកសុខាភិបាលព្រំដែន»** ដែលបានចុះហត្ថលេខាកាលពីឆ្នាំ២០០៦ និងបន្តជំរុញរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-វៀតណាម អនុវត្តឱ្យបានម៉ឺងម៉ាត់ទៅតាមវិធានការរបស់រដ្ឋាភិបាលនិងក្រសួងសុខាភិបាលនៃប្រទេសទាំងពីរ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនានាចូលទៅក្នុងសហគមន៍ភាគីម្ខាងទៀត ។

ភាគីទាំងពីរក៏បានអបអរសាទរពិធីផ្លាស់ប្តូរលិខិតូបករណ៍សច្ចាប័នលើសន្ធិសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាកំណត់ព្រំដែនរដ្ឋ និងពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោក ហើយបានស្វាគមន៍ចំពោះពិធីផ្លាស់ប្តូរផែនទីជានលេខាព្រំដែន កម្ពុជា-វៀតណាម ខ្នាត ១/២៥.០០០ រវាងគណៈកម្មការចម្រុះខណ្ឌសីមានិងបោះបង្គោលព្រំដែនគោកនៃប្រទេសទាំងពីរ ព្រមទាំងលើកទឹកចិត្តឱ្យគណៈកម្មការចម្រុះកិច្ចការព្រំដែននៃប្រទេសទាំងពីរ បន្តកិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធ និងធ្វើការពិភាក្សាគ្នាឱ្យបានសកម្ម ដើម្បីស្វែងរកដំណោះស្រាយអាចទទួលយកបានចំពោះខ្សែបន្ទាត់ព្រំដែននៅសេសសល់ប្រមាណ១៦% ។

ភាគីទាំងពីរលើកទឹកចិត្តឱ្យបណ្តាខេត្តជាប់ព្រំដែនបន្តកិច្ចសហប្រតិបត្តិការលើវិស័យនានាជាអាទិ៍ វិស័យអប់រំ វប្បធម៌ កីឡា យុត្តិធម៌ ឧស្សាហកម្ម បច្ចេកវិទ្យា នវានុវត្តន៍ បណ្តុះបណ្តាលធនធានមនុស្ស បណ្តុះបណ្តាលវិជ្ជាជីវៈ ព័ត៌មាន ប្រៃសណីយ៍ ទូរគមនាគមន៍ ព្រមទាំងបង្កើនកិច្ចសហប្រតិបត្តិការផ្សព្វផ្សាយអំពី សក្តានុពលទេសចរណ៍ ផលិតផលទេសចរណ៍ និងជំរុញសកម្មភាពទេសចរណ៍ និង កីឡា និងបន្តជួយឧបត្ថម្ភគ្នាទៅវិញទៅមករវាងបណ្តាខេត្តជាប់ព្រំដែន កម្ពុជា-វៀតណាម ឱ្យបានកាន់តែជិតស្និទ្ធថែមទៀត ។

ភាគីទាំងពីរក៏បានឯកភាពគ្នាក្នុងការរៀបចំកិច្ចប្រជុំលើកទី១២ ស្តីពីកិច្ចសហប្រតិបត្តិការនិងការអភិវឌ្ឍបណ្តាខេត្តជាប់ព្រំដែន កម្ពុជា-វៀតណាម នៅសាធារណរដ្ឋសង្គមនិយមវៀតណាមក្នុងឆ្នាំ ២០២២ ដោយកាលបរិច្ឆេទនិងទីកន្លែងប្រជុំជាក់ស្តែងនឹងត្រូវជូនដំណឹងតាមរយៈផ្លូវទូត ៕


## ព្យាបាល និងដាក់ធ្មេញមិនគិតថ្លៃ

**មន្ទីរពេទ្យ ១៦ ឧសភា** របស់នាយកដ្ឋានសុខាភិបាល អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ដែលមានទីតាំងនៅភូមិតាងៅក្រោម សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ។

សូមជូនដំណឹងដល់កងកម្លាំងនគរបាលជាតិ និងប្រជាជនទូទៅទាំងអស់ឱ្យបានជ្រាបថា : **មន្ទីរពេទ្យ ១៦ ឧសភា** បានរៀបចំព្យាបាលធ្មេញដោយឥតគិតថ្លៃ ។

**ក្នុងនោះមាន :**

- **ដកធ្មេញ**
- **សំអាតធ្មេញ**
- **ប៉ះធ្មេញ**
- **ព្យាបាលធ្មេញ**

**ចំពោះ**មន្ត្រីនគរបាលជាតិគ្រប់អង្គភាពទូទាំងប្រទេសដែលចង់មកទទួលសេវាដាក់ធ្មេញមិនមានគិតថ្លៃអ្វីទាំងអស់ត្រូវមាន ***(អត្តសញ្ញាណប័ណ្ណនគរបាល)*** ។

⁎ **<u>បញ្ជាក់</u>: ដោយឡែកប្រជាជនទូទៅមានតំលៃដូចខាងក្រោម :**

*-តម្លៃធ្មេញធម្មតា ១គ្រាប់ ១០$ (តម្លៃទីផ្សារខាងក្រៅ ១គ្រាប់ ៣០$*

*-តម្លៃធ្មេញ Ceramic ១គ្រាប់ ៣០$ (តម្លៃទីផ្សារខាងក្រៅ១គ្រាប់ ៨០$*

*ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ : 092 645 171, 015 75 79 79*





## វេជ្ជបណ្ឌិត ញ៉ែម សុខន

**បន្ទប់ពិនិត្យ ពិគ្រោះនិងព្យាបាលជម្ងឺទូទៅ**

**- ឯកទេសផ្នែកជំងឺទូទៅ និងរូបភាពវេជ្ជសាស្ត្រ**

មានពិនិត្យអេកូសាស្ត្រពណ៌ផ្នែក :

- សរីរាង្គក្នុងពោះមានៈ ថ្លើម, ប្រមាត់, លំពែង, បំពង់បង្ហូរទឹកប្រមាត់, តម្រងនោម។
- សរីរាង្គភេទស្ត្រីៈ ស្បូន, ដៃស្បូន, និងពិនិត្យផ្ទៃពោះ សរីរាង្គក្រពេញទារ៉ូអ៊ីដ : ពកក

**បញ្ចុះតម្លៃ ១០%** សម្រាប់មន្ត្រីនគរបាលជាតិ

**- មានបទពិសោធន៍ក្នុងការងារពិនិត្យ និងព្យាបាលជំងឺរយៈពេល ២០ឆ្នាំ ។**





អាសយដ្ឋានផ្ទះលេខ១៣៨អឺសូន្យ ផ្លូវ២១៥ (នេរូហ៍) សង្កាត់វាលវង់ ខណ្ឌ៧ មករា រាជធានីភ្នំពេញ (ខាងត្បូងស្តុបផ្សារដេប៉ូចម្ងាយ៥០ម៉ែត្រ)

ទូរស័ព្ទ: 097 2666 215 / 012 848 917



តមកពីទំព័រ ០៨

**កិច្ចប្រជុំលើកទី ១៩ ( គ ជ អ ប ) ដើម្បី....**





**សម្តេចក្រឡាហោម** បានមានប្រសាសន៍រំលឹកឡើងវិញផងដែរថា ៖ កម្ពុជាបានអនុវត្តបញ្ចប់កម្មវិធីជាតិរយៈពេល ១០ឆ្នាំ ដំណាក់កាលទី ១ ២០១០-២០២០ ដោយជោគជ័យនិងសម្រេចបាននូវសមិទ្ធផលធំៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំ និងដាក់ឱ្យដំណើរការស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមជាមួយការផ្ទេរមុខងារ និងធនធានចាំបាច់នានាទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការអភិវឌ្ឍន៍មូលដ្ឋាន ព្រមទាំងការផ្តល់សេវាសាធារណៈចាំបាច់នានាជូនប្រជាពលរដ្ឋ ។

**សម្តេចក្រឡាហោម** បានមានប្រសាសន៍បញ្ជាក់បន្ថែមទៀតថា ៖ ក្នុងគោលបំណងជម្រុញការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឲ្យកាន់តែស៊ីជម្រៅ រាជរដ្ឋាភិបាលបានសម្រេចឲ្យរៀបចំកម្មវិធីជាតិដំណាក់កាលទី ២ សម្រាប់រយៈពេល ១០ឆ្នាំបន្ថែមទៀត គឺចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០៣០ ដើម្បីបន្តពង្រឹងស្ថាប័នរដ្ឋបាល ថ្នាក់ក្រោមជាតិឱ្យកាន់តែមានសក្តានុពលក្នុងការចូលរួមចំណែកសម្រេចបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាល នោះគឺការស្តារស្ថានភាពសេដ្ឋកិច្ចជាតិក្រោយវិបត្តិកូវីដ-១៩ និងការបន្តជំរុញកម្ពុជាឱ្យក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នាពេលឆាប់ៗខាងមុខនេះ ។



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា




# ខ្ញី ទឹកឃ្មុំ និងក្រូចឆ្មា ជួយបំបាត់អាការៈឈឺបំពង់កយ៉ាងឆាប់រហ័ស

គ្មានអ្វីគួរឱ្យរំខាន និង ផ្ដល់អារម្មណ៍មិនស្រួលខ្លួន ដូចអាការៈឈឺបំពង់កឡើយ ប៉ុន្តែសូមកុំបារម្ភ យើងអាចព្យាបាលអាការៈឈឺបំពង់ក បានយ៉ាងឆាប់រហ័ស ដោយមិនបាច់ទាំងប្រើប្រាស់ថ្នាំពេទ្យ ។ មានរូបមន្តបែបធម្មជាតិ និងវិធីងាយៗដែលអាចព្យាបាលអាការៈឈឺបំពង់ក ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ៖

### ១. ទឹកអំបិលក្ដៅឧណ្ហៗ

អ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែលាយអំបិលកន្លះស្លាបព្រាកាហ្វេក្នុងទឹកក្ដៅឧណ្ហៗ ១ពែង រួចកូរអោយសព្វជាមុនសិន សឹមខ្ពុរមាត់របស់អ្នកជាមួយទឹកល្បាយនេះសម្រាប់រយៈពេលពី២ទៅ៣វិនាទី ។ អ្នកអាចអនុវត្តអោយបានពី ៣ ទៅ ៤ ដងក្នុងមួយថ្ងៃ ប្រសិនបើបំពង់កនៅឈឺ ។ ទឹកល្បាយនេះជួយបន្សាបជាតិអាស៊ីតក្នុងបំពង់ក និងបំបាត់អាការៈរលាក ។

### ២.ខ្ញី ទឹកឃ្មុំ និងទឹកក្រូចឆ្មារ

អ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែលាយទឹកឃ្មុំ ១ស្លាបព្រាកាហ្វេ, ម្សៅខ្ញី ឬខ្ញីម៉ដ្ឋ ១ស្លាបព្រាកាហ្វេ ជាមួយទឹកក្ដៅកន្លះពែង រួចសឹមបន្ថែមទឹកក្រូចឆ្មាស្រស់មួយចំណិតចូល កូរឱ្យសព្វ សឹមខ្ពុរមាត់ជាមួយទឹកល្បាយនេះដើម្បីបំបាត់អាការៈហើម និងឈឺចាប់ដែលបង្កឡើងដោយការឈឺបំពង់ក ។ អ្នកក៏អាចទទួលទានតែខ្ញីផងដែរ ខណៈដែលភេសជ្ជៈនេះមានលក្ខណៈសម្បត្តិប្រឆាំងការរលាកល្អសម្រាប់បំបាត់អាការៈឈឺបំពង់ក ។

### ៣. ទឹកឃ្មុំ

ទឹកឃ្មុំមានលក្ខណៈសម្បត្តិប្រឆាំងបាក់តេរីនិងល្អណាស់សម្រាប់ព្យាបាលរបួស ។ វាអាចជួយកម្ចាត់បាក់តេរី និងព្យាបាលការរលាកក្នុងបំពង់ក ។ អ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែលាយទឹកឃ្មុំក្នុងទឹកក្ដៅឧណ្ហៗ ឬទឹកតែ ហើយទទួលទានជាការស្រេច ។ អ្នកក៏អាចលាយទឹកឃ្មុំ ១ស្លាបព្រាពេញ ជាមួយទឹកក្រូចឆ្មារស្រស់បន្តិចក្នុងទឹកក្ដៅឧណ្ហ ១ កែវ កូរឱ្យសព្វ សឹមទទួលទានរហូតដល់អាការៈធូរស្បើយ ។

### ៤.ម្សៅ Baking soda

ម្សៅ Baking soda ជួយកម្ចាត់បាក់តេរី ទប់ស្កាត់មិនឱ្យវារីករាលដាល ក៏ដូចជាបំបែកស្លេសក្នុងបំពង់ក ។ អ្វីដែលអ្នកត្រូវធ្វើ គឺគ្រាន់តែលាយម្សៅ Baking soda កន្លះស្លាបព្រាកាហ្វេក្នុងទឹកក្ដៅឧណ្ហៗ ១កែវ រួចកូរឱ្យសព្វ សឹមខ្ពុរមាត់ជាមួយទឹកល្បាយនេះរៀងរាល់ពី ២ ទៅ ៣ម៉ោងម្ដងតាមការចាំបាច់ ។

ប្រភពពី Health.com.kh



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល




មនុស្សយើងភាគច្រើនតែងតែចាប់ផ្ដើមថ្ងៃថ្មីជាមួយនឹងកាហ្វេក្ដៅ ឬតែក្ដៅមួយពែងក្រោយពីភ្ញាក់ពីគេង ។ ប៉ុន្តែនៅពេលយើងញ៉ាំទឹកវិញ យើងតែងតែចង់ញ៉ាំទឹកត្រជាក់ ។ ទោះបីជាយ៉ាងណាក៏ដោយ ការញ៉ាំទឹកក្ដៅ ជាពិសេសនៅពេលព្រឹកវិញនោះ វាពិតជាមានអត្ថប្រយោជន៍ដល់ផ្លូវរំលាយអាហារ និងបញ្ចេញជាតិពុលពីក្នុងខ្លួន ។ ខាងក្រោមនេះគឺជាហេតុផលដែលអ្នកគួរតែញ៉ាំទឹកក្ដៅឧណ្ហៗព្រឹកឡើងពេលពោះទទេ ៖

**ច្រោះជាតិពុល**

ទឹកក្ដៅឧណ្ហៗមួយពែងរាល់ព្រឹកអាចលាងសម្អាតជាតិពុលពីក្នុងរាងកាយបាន ។ ទឹក និងសារធាតុផ្សំនឹងជំរុញដល់ការរំលាយម្ហូបគុណរបស់អាហារក្នុងក្រពះ និងថែរក្សាផ្លូវរំលាយអាហារកាន់តែល្អ ។ អ្នកក៏អាចញ៉ាំទឹកក្ដៅបានដែរក្រោយពីញ៉ាំអាហាររួចដើម្បីជំនួយដល់ប្រព័ន្ធរំលាយអាហារ ។

**បង្កើនការរំលាយអាហារ**

មិនយូរមិនឆាប់ មនុស្សយើងគ្រប់គ្នានឹងជួបបញ្ហាឈឺក្រពះ ឬ ចលនាពោះវៀនខ្សោយ ។ ការញ៉ាំទឹកក្ដៅឧណ្ហៗ មួយកែវនៅពោះទទេព្រឹកឡើងនឹងជួយបង្កើនការរំលាយអាហារ ព្រមទាំងជួយឱ្យរាងកាយធ្វើការងូចឆ្អឹងភាពវិញបានទៀត។

**បំបាត់ការឈឺចាប់**

គេជឿថា ទឹកក្ដៅឧណ្ហៗគឺជាឱសថធម្មជាតិដ៏មានថាមពលខ្លាំងក្លាបំផុត ហើយក៏អាចបំបាត់ការឈឺចាប់ពេលមករដូវបានដែរ ។ ជាតិក្ដៅនឹងទៅបន្ធូរសាច់ដុំពោះដែលជាហេតុនាំឱ្យថយចុះដល់ការឈឺចាប់ ហើយវាក៏ល្អណាស់ដែរចំពោះការឈឺចាប់បែបរមួលគ្រប់ប្រភេទ ព្រោះវាទៅជំរុញដល់របត់ឈាមរត់ដើម្បីបន្ធូរសាច់ដុំ ។

**សម្រកទម្ងន់**

បើសិនជាអ្នកត្រូវការញ៉ាំអាហារ អ្នកប្រហែលជាធ្លាប់លឺថា ការញ៉ាំទឹកក្ដៅឧណ្ហៗមួយកែវនៅពេលព្រឹកនឹងជួយសម្រកទម្ងន់បាន ។ តាមពិតទឹកក្ដៅជួយបង្កើនសីតុណ្ហភាពរាងកាយ និងសម្រួលដល់ការរំលាយអាហារ ។ ហេតុដូច្នេះហើយរាងកាយនឹងរំលាយជាតិខ្លាញ់កាន់តែច្រើន ។ អ្នកនឹងទទួលបានប្រយោជន៍មួយទៀតលើកម្រិងនោមនិងអាចបញ្ចេញជាតិពុលបានថែមទៀតផង ។

**ពង្រឹងដល់របត់ឈាមរត់**

ការញ៉ាំទឹកក្ដៅឧណ្ហៗនឹងធ្វើឱ្យរាងកាយគ្មានជាតិពុលដែលគ្រោះថ្នាក់ ។ ហេតុដូច្នេះហើយ ទើបវាពង្រឹងដល់របត់ឈាមរត់បាន ។

**បន្ថយភាពចាស់**

ការចាស់មុនអាយុគឺជាសុបិន្តអាក្រក់របស់ស្ត្រីគ្រប់រូប ។ សំណាងដែររឿងនេះអាចបង្ការបានតាមរយៈការញ៉ាំទឹកក្ដៅឧណ្ហៗ ។ វត្តមានជាតិពុលក្នុងរាងកាយនឹងបង្កើនល្បឿននៃភាពចាស់ ហើយចាប់តាំងពីទឹកក្ដៅអាចបញ្ចេញជាតិពុលទាំងនេះបានមក វាក៏អាចបន្ថយដំណើរនៃភាពចាស់ និងបង្កើនភាពយឺតកាន់តែច្រើនដល់ស្បែកទៀតដែរ ៕

ប្រភពពី Health.com.kh



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា







SK Teeth Whitening Powder

ជាប្រភេទម្សៅដុសធ្មេញឲ្យស សម្រាប់អ្នកដែលមិនមានពេលទំនេរច្រើន ។ ហើយក៏អាចប្រើជាមួយឈុត Home Kit សម្រាប់ប្រភេទធ្មេញល្បឿងខ្លាំងពីកំណើត ។ លក្ខណៈពិសេសរបស់វាគឺមានតួនាទីជួយសំអាតជាតិកំបោរលើធ្មេញបានយ៉ាងល្អ ។ ប្រើរយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។

SK Luxury Kit

ជាប្រភេទពន្លឺធ្វើអោយធ្មេញស ដែលមានមុខងារពិសេស។ ជាច្រើនរួមបញ្ចូលគ្នាក្នុងប្រអប់ Luxury Kit តែមួយ ។ មានវីតាមីនជួយការពារធ្មេញ អញ្ចាញធ្មេញ និងការពារស្រៀវស្រគា។ Luxury Kit Design ឡើងយ៉ាងសាកសមបំផុតសម្រាប់មនុស្សសម័យថ្មី ថ្លៃថ្នូរជាមួយនិងបច្ចេកវិទ្យាទំនើប និងការវិចខ្ចប់ដ៏ស្រស់ស្អាត។ អាចធ្វើជាការជូនមនុស្សជាទីស្រលាញ់ ។ ប្រើប្រាស់រយៈពេល៧ថ្ងៃឃើញលទ្ធផល។







Set Luxury + Powder

ឈុតពិសេសសំរាប់ធ្មេញល្បឿងខ្លាំងពីកំណើត

-ប្រើបាន ២៤ ដង　　-គុណភាពសល្បឿន គុណនិង២
-មានអនាម័យខ្ពស់ ការវិចខ្ចប់ខ្ពស់　　-មានវិតាមីន C ការពារអញ្ចាញ
-មាន Florine ការពារធ្មេញពុក　　-មាន Potassium nitrate ការពារស្រៀវ ស្រគាធ្មេញ
-ជួយធ្វើអោយធ្មេញភ្លឺរលោង សស្អាត កំចាត់កំនរកំបោរ និងស្នឹបខ្មៅៗ
លើធ្មេញប្រើរយៈពេល ៥ថ្ងៃ ចាប់ផ្តើមឃើញធ្វើប្លែក ។

SK Home Kit Teeth Whitening

សម្រាប់ប្រភេទធ្មេញធម្មតាជាប្រភេទពន្លឺធ្វើអោយធ្មេញស ប្រើដោយខ្លួនឯងនៅផ្ទះ ដោយមិនចាំបាច់ចំណាយពេលវេលា Clinic សម្រាប់ប្រភេទធ្មេញល្បឿងធម្មតា មិនស្រៀវ មិនល្បឿងពីកំណើត ប្រើប្រាស់រយៈពេល ៧ថ្ងៃ ចាប់ផ្តើមឃើញលទ្ធផល ។







Madamk Menbrane Gel

ជួយផ្តល់សំណើមយ៉ាងល្អដល់ស្បែកមុខ
បំបាត់នូវបញ្ហា
-រមាស់ -ក្របាម -របកស្បែក -រលាក




Madamk Healing Set Membrane Gel Add Oil

ជាប្រភេទឡេលាបថែរក្សា និង បំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ អាចំរុយ ហើយជួយផ្តល់សំណើមដល់ស្បែក និងជួយបំបាត់រាល់បញ្ហារមាស់ក្របាមខ្លាំង របកស្បែករលាក ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និង ក្រាស់ឡើញវិញ ។

Madamk Healing Set

ជាប្រភេទឡេលាបថែរក្សា និងបំបនស្បែកមុខ វាជួយអោយមុខយើងសភ្លឺមរ្ឌរលោង ការពារមុខជាំ អាចម៍រុយ និងជ្រួញ ហើយថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្តើងសរសៃក្រហាមផងដែរ ។ លក្ខណៈពិសេសគឺអាចជួយបឺតយកសារជាតិពុលចេញពីមុខរបស់អ្នក ដែលបន្សល់មកពីផលិតផលចាស់ៗ ដែលមានសារធាតុថ្នាំ និងធ្វើអោយស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើញវិញ ។

ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឫស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839




Madamk Aromatic Nourishing Face Oil

មានមុខងារ

-ជួយបំបាត់មុខក្រហម

-ជួយបំបាត់មុខស្តើងសរសៃក្រហម

-ជួយស្បែកមានជាតិទឹក ភ្លឺរលោងក្មេងជាងវ័យ
ចំពោះអ្នកមានអាយុលើសពី ៣០ឆ្នាំ ឡើងទៅប្រើ Oil
នេះរាល់ថ្ងៃវាជួយផ្តល់ជាតិទឹក អោយមុខក្មេងជាងវ័យ
និងពន្យាភាពចាស់ផងដែរ។

Madamk Hair Shampoo & Hair Conditioner

មុខងារ :

-ជួយបណ្តុះសក់

-ជួយព្យាបាលសរសៃសក់ដែលខូចខ្លាំង

-ជួយធ្វើអោយសក់ទន់រលោងក្រអូបនិងជួយអោយសក់រឹងមាំ

-លាងជំរះស្បែកក្បាលបានល្អ បំបាត់អង្គែ និងរមាស់




Madamk Advance Eye Essence

-ជាសេរ៉ូលាបភ្នែក វាមានតួនាទី២យ៉ាង ទី១
ព្យាបាល ទី២ បញ្ជោតភ្លាមៗ

-ជួយអោយភ្នែកបាត់ខ្មៅ បាត់ស្លក់ បាត់ជ្រួញ

-លាបភ្លាមឃើញភ្នែកអន់ខ្មៅ អន់ជ្រួញ អន់ស្លក់ភ្លាមៗ
២០-៣០% (លាងទឹកត្រលប់មកធម្មតាវិញ)

-លាបរយៈពេល ៣ខែឡើង ចាប់ផ្តើមឃើញលទ្ធផល

-លាបចូលអស់មិនកក លាបច្រើនយ៉ាងណាក៏មិនកក
និងអាចលាបនៅកន្លែងណាដែលមានស្នាមជ្រួញបានផលដែរ។







Madamk Qwhite Body Lotion

ជាឡេលាបខ្លួនអោយស្បែក ស មង្គរលោង
វាមានតួនាទី ៣យ៉ាង :

ទី១ បញ្ជោតអោយ ស ភ្លាម

ទី២ ធ្វើអោយស្បែក ស ពីខាងក្នុងពិតប្រាកដ

ទី៣ ជួយការពារកំដៅថ្ងៃបានយ៉ាងល្អ។
(លាងទឹកត្រលប់មកធម្មតាវិញ)

-លាបចាប់ពី ៣ខែ ឡើងទើបឃើញលទ្ធផល
ស្បែកសភ្លឺចេញពីក្នុង

-ស បែបស្បែកមានសុខភាពល្អ

-ជួយការពារកម្តៅថ្ងៃបានយ៉ាងល្អ SPF 25
រយៈពេល ៣ខែឡើងចាប់ផ្តើមឃើញលទ្ធផល




Madamk Herbal Cream ជា Cream

ផ្សំពីផ្កា ឫសឈើ និងម្សៅគុជខ្យងជួយ :

-បឺតជាតិពុល ជាតិថ្នាំគីមីពីក្រោមស្បែកមុខដែល
បន្សល់ពីផលិតផលចាស់

-បំបាត់អាល វីមុខ

-ជួយផ្អិតរុន្ធញើស

-ជួយអោយមុខភ្លឺរលោង






Madamk Healing Specail

ជាប្រភេទឡេលាបថែរក្សា និងបំប៉នស្បែកមុខ
វាជួយអោយមុខយើងសភ្លឺរលោង ការពារមុខជាំ
អាចម៉ុយ ហើយជួយផ្តល់សំណើមដល់ស្បែក
និងជួយបំបាត់អាល វី មុនកប់ ជួយផ្អិតរុញញើស
ថែមទាំងអាចបំបាត់ស្នាមលើផ្ទៃមុខផងដែរ
ម្យ៉ាងទៀតវាអាចជួយអោយស្បែកបាត់ស្តើងសរសៃក្រហម
បានផងដែរ ។ លក្ខណៈពិសេស គឺអាចជួយបឺតយក
សារជាតិពុលចេញពីមុខរបស់អ្នកដែលបន្សល់មកពី
ផលិតផលចាស់ៗដែលមានសារធាតុថ្នាំ និងធ្វើអោយ
ស្បែកមុខអ្នកមានសុខភាពស្បែកមុខល្អ និងក្រាស់ឡើញវិញ។

Madamk Armpit Scrub ជាសាប៊ូដុះពេលងូតទឹក

-ជួយបំបាត់ក្លិនក្លៀកភ្លាមៗក្រោយពេលងូតទឹករួច

-ជួយអោយក្លៀក ស មង្គ បាត់រុំពក មិនមានជាតិថ្នាំពេទ្យ
ដែលប៉ះពាល់ស្បែកក្លៀកទេ។

ផ្ទះលេខ 100 ផ្លូវ 164 សង្កាត់អូរឫស្សី ខណ្ឌ7មករា ទូរស័ព្ទ : 017 777 839 / 016 777 839









តមកពីទំព័រ ១៤

**ឆមាសទី ១ ឆ្នាំ ២០២១ គ្រោះថ្នាក់ចរាចរណ៍.....**








រអំពីច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក ចែកស្ទីកឃ័រចំណាំងផ្លាត និងមួកសុវត្ថិភាពដល់អ្នកបើកបរទោចក្រយានយន្ត បន្តសិក្សាត្រួតពិនិត្យតំបន់ដែលមានគ្រោះថ្នាក់ញឹកញាប់ និងកែលម្អទីតាំងទាំងនោះ បំពាក់កាមេរ៉ាសុវត្ថិភាព និងផ្លាកសញ្ញាចរាចរណ៍ សិក្សានិងរៀបចំវិធានការបំពាក់ប្រព័ន្ធ GPS តាមដានល្បឿនយានយន្តដឹកទំនិញ ជំរុញការដឹកជញ្ជូនទំនិញតាមផ្លូវដែក ដើម្បីកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍និងការខូចខាតផ្លូវថ្នល់សហការជាមួយអនុគណៈកម្មការទី២ក្នុងការត្រួតពិនិត្យយានយន្តដែលផុតសុពលភាពលើឿកបន្តដួសជុល ថែទាំ និងអភិវឌ្ឍផ្លូវស្ពាន ដើម្បីធានានិរន្តរភាពនិងលើកកម្ពស់ប្រសិទ្ធភាពចរាចរណ៍ដឹកជញ្ជូន ដើម្បីកំណើនសេដ្ឋកិច្ច និងសង្គម ។

អញ្ជើញមានប្រសាសន៍ក្នុងកិច្ចប្រជុំនោះ **សម្តេចក្រឡាហោម** បានវាយតម្លៃចំពោះកិច្ចខិតខំប្រឹងប្រែងរបស់យន្តការពាក់ព័ន្ធ ដោយបានចាត់តាំងអនុវត្តនូវយុទ្ធសាស្ត្រ និងផែនការរបស់ គ.ស.ច.គ ប្រកបដោយភាពទន់ភ្លន់ តែម៉ឺងម៉ាត់មានភាពរស់រវើក និងមានស្មារតីទទួលខុសត្រូវខ្ពស់ មានការចូលរួមគោរព និងអនុវត្តច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកយ៉ាងច្រើនកុះករពីសំណាក់ប្រជាពលរដ្ឋដែលជាអ្នកប្រើប្រាស់ផ្លូវ ជាពិសេសនោះមានការចូលរួមពីបណ្តាប្រទេសអង្គការជាតិ និងអន្តរជាតិក្នុងការផ្តល់ជំនួយបច្ចេកទេស និងសម្ភារ លើវិស័យសុវត្ថិភាពចរាចរណ៍ផ្លូវគោក។

ទន្ទឹមនេះជាមួយប្រសាសន៍គាំទ្រចំពោះទិសដៅសំខាន់ៗសម្រាប់អនុវត្តក្នុងឆមាសទីពីរ **សម្តេចក្រឡាហោម** ក៏បានស្នើឱ្យមានយន្តការពាក់ព័ន្ធគ្រប់ថ្នាក់យកចិត្តទុកដាក់បន្ថែមលើកិច្ចការសំខាន់ៗមួយចំនួនដូចជា ៖ អនុគណៈកម្មការទី១ត្រូវបន្តធ្វើការរឹតបន្តឹងអនុវត្តច្បាប់ដោយប្រើប្រាស់ឧបករណ៍បច្ចេកទេសទំនើប ដើម្បីទប់ស្កាត់បទល្មើសចរាចរណ៍ និងបទល្មើសផ្សេងៗឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងនិរន្តរភាព និងត្រូវយកចិត្តទុកដាក់ថែមទៀតក្នុងការបំពាក់ភ្លើងស្តុប ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ ដើម្បីធានាឱ្យផ្លូវថ្នល់មានសុវត្ថិភាព និងត្រូវបន្តគាំទ្រដល់ការបំពាក់កាមេរ៉ាត្រួតពិនិត្យល្បឿនរថយន្តនៅតាមផ្លូវជាតិនានា តាមរយៈការបញ្ចូលគម្រោងបំពាក់នេះ ទៅក្នុងគម្រោងកសាង ឬជួសជុលផ្លូវ ។ ព្រមជាមួយនោះ អភិបាលរាជធានី-ខេត្តត្រូវយកចិត្តទុកដាក់បំពាក់ភ្លើងស្តុប ស្លាកសញ្ញា និងគំនូសសញ្ញាចរាចរណ៍ និងរឹតបណ្តឹងឱ្យបានម៉ឺងម៉ាត់លើការដឹកជញ្ជូនដី ខ្សាច់ ថ្ម ផ្ទុះវាយប៉ាយនៅតាមផ្លូវក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ៕



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល



តមកពីទំព័រ ៣០

**អគារទីស្នាក់ការ ច្រកទ្វារព្រំដែនអន្តរជាតិ.....**

គួរបញ្ជាក់ផងដែរថា៖ អគារទីស្នាក់ការច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត( កម្ពុជា-ថៃ) ចាប់ផ្តើមសាងសង់ឡើងពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២១ និងបញ្ចប់រួចរាល់ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ ដែលសាងសង់ដោយកងកម្លាំងនាយកដ្ឋានស្ថាបនា និងវិស្វកម្ម អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ដោយចំណាយថវិកាអស់ ១៧,០១៣,០០០,០០០រៀល ។ ក្នុងពិធីប្រគល់-ទទួលនោះដែរមានការអញ្ជើញចូលរួមពីសំណាក់តំណាងក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលក្រុងប៉ោយប៉ែត និងតំណាងប្រធានស្នាក់ការច្រកទ្វារអន្តរជាតិប៉ោយប៉ែត ។







៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា


SINCE 1997
WWW.SOKHAGROUP.COM
E: SOKHASUN@SOKHAGROUP.COM
Cell: 012 / 070 8 7777 6
SOKHA
PRINTING HOUSE
#970, STREET BETONG, PHUM ROUNG CHAK,
SANGKAT PHNOM PENH THMEY, KHAN SEN SOK
WE KNOW,
WHAT YOU WANT
MAGAZINE • CATALOGUE • MENU • BOOKLET • ANNUAL REPORT • DIARY • NOTEBOOK • BROCHURE • FLYER • CORPORATE IDENTITY • FOLDER •
CALENDAR • PAPER BAG • PLASTIC BAG • ECO BAG • KEY CHAIN • HAND FAN • PARASOL/UMBRELLA • PEN • T-SHIRT • CAP • BAG • CAKE BOX
• MEDICAL BOX • POSTER • BANNER • BILLBOARD • PRE-PAID CARD • ID CARD • CHEQUE • SECURITY CARD


VHP
VHP Global Co., Ltd.
ទឹកបរិធម្មជាតិ
ដើម្បីសុខភាព
ទិញឥឡូវនេះ ទទួលបាន
1 ឆ្នាំ
ធានាជូនសេវាកម្មបច្ចេកទេស
- ដឹកជញ្ជូនមិនគិតថ្លៃ
- ដំឡើងមិនគិតថ្លៃ
កង្ហាល Hatari
MODEL: W2-340S MODEL: HWJ-110 MODEL: W2-320 MODEL: W2-340
HOT COLD 4 FILTER FUNCTION
HWJ-110 13L
W2-320 10L
W2-340 27L
W2-340s 11L
W2-160p 10L
W2-320WH 9L
W2-320H 9L
W2-1000 10L
WH-UP 200 90L/H
HU-800 90L/H
មុខងារតម្រង់ 4 FILTER FUNCTION
Sediment
ច្រោះកករ
(៣ខែប្តូរម្តង)
Pre -Carbon
ច្រោះសារធាតុគីមី
(៦ខែប្តូរម្តង)
Post -Carbon
បង្កើនរសជាតិទឹក
(៩ខែប្តូរម្តង)
UF -Membrane
កំចាត់មេរោគក្នុងទឹក
(១២ខែប្តូរម្តង)
មេដាយទទួលស្គាល់ពី អាមេរិក អឺរ៉ុប និងកូរ៉េ
ត្រូវការតំណាងលក់ផ្តាច់មុខតាមតំបន់នីមួយៗ
VHP Globle
www.hyundaiwater.com
023 6666 919 / 069 5000 86
HYUNDAI
WACORTEC
ម៉ាស៊ីនចម្រោះទឹក
ពត៌មានបន្ថែម
អាស័យដ្ឋាន : ផ្ទះលេខ ៣៨C ផ្លូវ ៨០៨ សង្កាត់ទួលទំពូង॥
ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល : info@vhp-global.com / facebook.com/vhp.global




មួយរយៈចុងក្រោយនេះ សភាពប្រែប្រួលនៃបរិយាកាសបានកើនឡើងយ៉ាងឆាប់រហ័សណាស់ ដែលតាមការសិក្សាស្រាវជ្រាវរបស់ក្រុមអ្នកវិទ្យាសាស្ត្របានលើកឡើងថា ការប្រែប្រួលបរិយាកាសដែលនាំឱ្យមានការកើនឡើងនូវកំដៅគ្រោះរាំងស្ងួត និងទឹកជំនន់នៅពាសពេញពិភពលោក គឺជាការរួមចំណែកដ៏សំខាន់បំផុតពីសកម្មភាពរបស់មនុស្សក្នុងរយៈពេល ១០០ឆ្នាំ ចុងក្រោយកន្លងមកនេះ។ តាមរយៈរបាយការណ៍មួយដែលចេញផ្សាយដោយក្រុមអន្តររដ្ឋាភិបាលនៃក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពី ការប្រែប្រួលបរិយាកាសឬហៅកាត់ថា(IPCC) ដែលបានធ្វើការសិក្សាស្រាវជ្រាវកាលពី ៨ឆ្នាំមុន ហើយទើបតែចេញផ្សាយកាលពីពេលថ្មីៗកន្លងទៅបានឱ្យដឹងថា ដោយសារតែ ការ ប ញ្ចេ ញ ការបោន ចូល ទៅក្នុងបរិយាកាសច្រើនជាងពេលណាៗទាំងអស់



បានញុំាងកំដៅឱ្យកើនឡើងរហូតដល់ទៅ១.៥អង្សាសេ ។

ក្នុងរបាយការណ៍ដដែលនេះបានគូសបញ្ជាក់បន្តទៀតថា ពិភពលោកទាំងមូលត្រូវតែកាត់បន្ថយការបញ្ចេញការបោនឱ្យច្រើនបំផុតនៅឆ្នាំ២០៣០ និងត្រូវកាត់បន្ថែមទៀតរហូតដល់កំរិតសូន្យនៅឆ្នាំ២០៥០ ទើបអាចជួយសង្គ្រោះនិងទប់ស្កាត់បានអំពីការកើនឡើងនូវកំដៅសកល បើពុំនោះសោតទេមហន្តរាយដែលបង្កឡើងដោយសារតែការប្រែប្រួលបរិយាកាសនេះវានឹងនាំឲ្យគ្រោះមហន្តរាយធំធេងដល់ភពផែនដីរបស់យើងក្នុងនោះរួមមានគ្រោះទឹកជំនន់កាន់តែខ្លាំង កំដៅកាន់តែកើន ជាហេតុធ្វើឱ្យមានភ្លើងឆេះព្រៃជាដើម ។

ការប្រែប្រួលបរិយាកាសនេះបានស្តែងឡើងក្នុងទិដ្ឋភាពជាក់ស្តែងរួចទៅ


៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល






ហើយនៅជុំវិញពិភពលោកដែលយើងអាចដឹងបានតាមរយៈបណ្តាញផ្សព្វផ្សាយជាញឹកញាប់ ដូចជាការរលាយដុំផ្ទាំងទឹកកកធំឆាប់រហ័សហួសពីការរំពឹងទុកខ្យល់ព្យុះកាន់តែញឹកញាប់និងកាន់តែសាហាវ ។ នៅក្នុងឆ្នាំ២០២១ ទឹកភ្លៀងបានបង្ករហួសពីការរំពឹងទុកទៅទៀតជាហេតុនាំឱ្យមានទឹកជំនន់ដោយឥតព្រាងទុកជាពិសេសនៅតំបន់ភាគកណ្តាលប្រទេសចិន និងនៅក្នុងតំបន់អឺរ៉ុប ស្របពេលដែលភ្លើងឆេះព្រៃ នៅតែបន្តកើតមានឡើងនៅឡើយនៅពាសពេញតំបន់ស៊ីបេរីភាគខាងលិចសហរដ្ឋអាមេរិក និងតំបន់មេឌីទែ "រ៉ាណេជាដើម ។

៥៣









តមកពីទំព័រ ៥២

## សង្គ្រោះផែនដី គឺសង្គ្រោះជីវិតយើង...

នៅកំឡុងខែ សីហា ឆ្នាំ ២០២១ កន្លងមកនេះទឹកភ្លៀងបានបង្កឱ្យមានទឹកជំនន់យ៉ាងកំហុកនៅក្នុងខេត្តស៊ីឈួន ប្រទេសចិន ហើយអាជ្ញាធរបានបង្ខំចិត្តជន្លៀសពលរដ្ឋនៅក្នុងខេត្តរហូតដល់ទៅ ៨ម៉ឺននាក់ ។ មិនតែប៉ុណ្ណោះទឹកជំនន់បានបង្កឱ្យប៉ះពាល់ ដល់ពលរដ្ឋប្រមាណជា ៤៤ម៉ឺននាក់ឯណោះ នៅតាមទីប្រជុំជនរហូតដល់ទៅ៦ទីតាំងក្នុងខេត្តស៊ីឈួន ភាគនិរតីប្រទេសចិន ។

ដោយឡែកបណ្តាញផ្សព្វផ្សាយរបស់រដ្ឋចិនបានឱ្យដឹងបន្ថែមទៀតថា ទឹកជំនន់ដែលបង្កមកពីទឹកភ្លៀងបានបង្កឱ្យមានការខូចខាតទៅលើវិស័យសេដ្ឋកិច្ចអស់ប្រមាណជា ២៥០លានយ័ន្ត( ៣៨.៥៧លាន ដុល្លារអាមេរិក) នៅក្នុងខេត្តស៊ីឈួន ។ មិនតែប៉ុណ្ណោះបានបំផ្លិចបំផ្លាញផ្ទះសម្បែងរបស់ប្រជាពលរដ្ឋអស់ចំនួន ៤៥ខ្នង ខូចខាតធ្ងន់ធ្ងររហូតដល់ទៅ ១១៨ខ្នង ។

កាលពីខែកក្កដា កន្លងទៅ ក្នុងខេត្តហេណាន ភាគកណ្តាលប្រទេសចិន បានរងគ្រោះធ្ងន់ធ្ងរដោយសារតែខ្យល់ព្យុះសង្ឃរាដែលគេចាត់ទុកថា ជាខ្យល់ព្យុះដ៏មហិមាក្នុងប្រវត្តិសាស្ត្រចិន ព្រោះថាកាលណោះកម្លាំងខ្យល់បោកបក់បានធ្វើឱ្យប៉ះពាល់ដល់ស្ថានីយតាមដានវាស់ពីអាកាសធាតុរហូតដល់ទៅ ១៩ស្ថានីយឯណោះព្រោះវាមានការប្រែប្រួលញឹកញាប់ខ្លាំង ។នៅក្នុងខែដដែលនោះ ទឹកជំនន់បានសម្លាប់មនុស្សរហូតដល់ទៅ៣០០នាក់ ភាគច្រើនប៉ះទៅលើពលរដ្ឋរស់នៅតាមទីរួមខេត្តចេងហ្ស៊ូ ។ ការប្រែប្រួលអាកាសធាតុមិនមែនត្រឹមតែប៉ះពាល់ទៅលើតែប្រទេសចិនមួយប៉ុណ្ណោះទេ ប៉ុន្តែវាបានបង្កហានិភ័យដល់បណ្តាប្រទេសផ្សេងទៀត ។ ជាក់ស្តែងនៅក្នុងប្រទេសក្រិច ភ្លើងឆេះព្រៃបានកើតមានឡើងសារជាថ្មីម្តងទៀតនៅលើកោះអឺវីយ៉ា (Evia )បង្ខំឱ្យជន្លៀសពលរដ្ឋចាកចេញពីកោះដែលមានភ្លើងឆេះរហូតដល់ទៅ ២000នាក់ ។ ដើម្បីគ្រប់គ្រងស្ថានការណ៍អំពីភ្លើងឆេះព្រៃបាន អាជ្ញាធរប្រទេសក្រិចបានប្រើប្រាស់កម្លាំងមនុស្សពន្លត់ភ្លើងរហូតដល់ទៅ ២៦០នាក់ ដោយមានការចូលរួមពីក្រុមអ្នកជំនាញការផ្នែកអគ្គិភ័យមកពីបណ្តាប្រទេសនានារួមមានអ៊ុយក្រែន រ៉ូម៉ានី រួមទាំងទទួលកិច្ចគាំពារពីយន្តហោះពន្លត់អគ្គិភ័យពីលើអាកាសប្រមាណជា ១៧គ្រឿង និងរថយន្តនៅលើដីដើម្បីជួយពន្លត់បន្ថែមទៀតដល់ទៅ ៦៦គ្រឿង ។ ប្រទេសបារាំង អេស្ប៉ាញ អង់គ្លេស និងស៊ុយបៀ ក៏ស្ថិតនៅក្នុងចំណោមប្រទេសដែលបានបញ្ជូនក្រុមការងារពន្លត់អគ្គិភ័យចូលមកជួយប្រទេសក្រិចនេះដែរ ។

ក្រុមអ្នកឯកទេសផ្នែកបរិស្ថានបានលើកឡើងថា ភ្លើងឆេះព្រៃនៅក្នុងប្រទេសក្រិចលើកនេះមានវិសាលភាពធំធេងក្នុងរយៈពេល៣ទសវត្សរ៍កន្លងមក គឺបង្កមកពីការប្រែប្រួលបរិយាកាសរបស់ផែនដី ។ ត្រឹមតែរយៈពេល១០ថ្ងៃនៅក្នុងខែសីហា ភ្លើងព្រៃបានលេបត្របាក់ផ្ទៃដីដែលមានព្រៃឈើ រហូតដល់ទៅ ៥៦,000ហិចតា និងស្លាប់មនុស្ស ២នាក់ បូករួមទាំងមន្ត្រីពន្លត់ភ្លើងព្រៃផងដែរ ។

ងាកទៅមើលសហរដ្ឋអាមេរិកឯណោះវិញម្តង ភ្លើងឆេះព្រៃបានកើតមានឡើងនៅក្នុងតំបន់ភាគខាងជើងរដ្ឋកាលីហ្វ័រញ៉ា ដែលគេចាត់ទុកថាជាគ្រោះអាសន្នធំលំដាប់ទី២ នៅក្នុងប្រវត្តិសាស្ត្រប្រចាំរដ្ឋកាលីហ្វ័រញ៉ា ។ ក្រុមមន្ត្រីរដ្ឋកាលីហ្វ័រញ៉ា បានថ្លែងប្រាប់បណ្តាញផ្សព្វ



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល





ផ្សាយថា ភ្លើងឆេះព្រៃបានបំផ្លាញផ្ទៃដីដែលមានព្រៃឈើរហូតដល់ទៅ១,៨៧៦ គីឡូម៉ែត្រក្រឡា ។ ទោះបីជាបែបណាក៏ដោយចុះ ក៏ក្រុមមន្ត្រីនានារបស់រដ្ឋបានបន្តប្រាប់ប្រព័ន្ធផ្សព្វផ្សាយថាគេមិនទាន់ដឹងមូលហេតុពិតនៅពីក្រោយនៃការឆេះនេះនៅឡើយទេ ស្របពេលដែលមានការសន្និដ្ឋានជាបឋមថាទំនងជាអាចបង្កឡើងពីការដាច់ចរន្តខ្សែភ្លើងដែលចម្លងអគ្គិសនីទើបបណ្ដាលឱ្យមានអគ្គិភ័យឆាបឆេះឡើង ។

## ចុះខាសនានៅក្នុងតំបន់អាស៊ីខាងត្បូងវិញ?

ដោយយោងទៅលើរបាយការណ៍របស់ក្រុមអ្នកសិក្សាស្រាវជ្រាវអន្តររដ្ឋាភិបាលស្ដីពីការប្រែប្រួលអាកាសធាតុ (IPCC) បានចេញផ្សាយថា តំបន់អាស៊ីភាគខាងត្បូងអាចនឹងកើនឡើងនូវរលកកំដៅខ្លាំងនៅក្នុងសតវត្សរ៍ទី ២១នេះ ។ ការឆាប់រលាយផ្ទាំងទឹកកកនៅតំបន់អឌ្ឍគោលភាគខាងជើងបានបង្កឱ្យកើនឡើងនូវកំរិតទឹកសមុទ្រ ជាហេតុនាំឱ្យជន់លិចលង់ចំពោះប្រទេសទាំងឡាយណាដែលស្ថិតនៅក្នុងតំបន់ទំនាប និងឈានដល់លិចតំបន់ខ្លះទាំងស្រុងទៀតផងដែរ ។

នៅក្នុងរបាយការណ៍ដដែលបានគូសបញ្ជាក់បន្ថែមទៀតថា ក្នុងរយៈពេល ១០ទសវត្សរ៍កន្លងមក ជារៀងរាល់ឆ្នាំមានមនុស្សមិនក្រោមពី ២០លាននាក់ ទេដែលត្រូវបង្ខំចិត្តចាកចេញពីផ្ទះសម្បែងរបស់ខ្លួនដោយសារតែមហន្តរាយធម្មជាតិ ។ អង្គការ Oxfam ឯណោះវិញក៏បាននិយាយដែរថាក្នុងពេល៣០ឆ្នាំចុងក្រោយ ភពផែនដីទទួលបណ្ដាសារពីមហន្តរាយធម្មជាតិកើនឡើងដល់ទៅ៣ដងឯណោះ ។

រីឯអង្គការសហប្រជាជាតិវិញបានធ្វើការប៉ាន់ប្រមាណថា មានមនុស្សមិនក្រោមពី ១.២៣លាននាក់ ទេបានស្លាប់នៅទូទាំងពិភពលោក និង៤.២ពាន់លាននាក់ ផ្សេងទៀតទទួលរងគ្រោះដោយសារតែគ្រោះរាំងស្ងួត ទឹកជំនន់ និងភ្លើងឆេះព្រៃ ចាប់តាំងពីឆ្នាំ២០០០ រហូតមក។

ចំពោះប្រទេសឥណ្ឌា ដែលជាប្រទេសមួយនៅក្នុងចំណោមប្រទេសផ្សេងទៀតស្ថិតនៅក្នុងតំបន់អាស៊ីខាង

៥៥



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

22/5/23, 10:10 AM



តមកពីទំព័រ ៥៤

## សង្គ្រោះផែនដី គឺសង្គ្រោះជីវិតយើង...

ក្បែរវិញ គេបានធ្វើការវាយតម្លៃដោយក្រុមរដ្ឋាភិបាលខ្លួនឯងរកឃើញថា ចន្លោះពីឆ្នាំ១៩៥១ រហូតដល់ឆ្នាំ២០១៦ គឺជាឆ្នាំដែលមានការកើនឡើងគ្រោះរាំងស្ងួតខ្លាំង និងកើតឡើងជាញឹកញាប់ជាងពាក់កណ្ដាលសតវត្សរ៍កន្លងទៅ ។

ផ្អែកតាមវិទ្យាស្ថានធនធានពិភពលោក និងវិទ្យាស្ថានអភិវឌ្ឍបរទេសបានបង្ហាញរបាយការណ៍ស្រាវជ្រាវរបស់ខ្លួនថា ប្រទេសឥណ្ឌា គឺជាប្រទេសមួយស្ថិតនៅក្នុងចំណោមប្រទេសចំនួន១៧ ផ្សេងទៀតដែលរងគ្រោះខ្លាំងដោយសារតែកង្វះទឹកឈានដល់គ្រោះរាំងស្ងួត ក្នុងនោះប្រទេសស្ថិតនៅក្នុងតំបន់មជ្ឈិមបូព៌ា អាហ្វ្រិកភាគខាងជើង ជាតំបន់មានវាលខ្សាច់រហោស្ថាន ។

ទាក់ទិននឹងការប្រែប្រួលបរិយាកាសនេះដដែល ការរកឃើញរបស់វិទ្យាស្ថានទាំងពីរខាងលើនោះ បានរំលេចថែមទៀតថា គ្រាន់តែឆ្នាំ ២០២០កន្លងទៅមានមហាព្រឹត្តិការណ៍គ្រោះអាសន្នកើតឡើងតែមួយមុខក្នុងឆ្នាំនោះព្រោះតែទឹកជំនន់បង្កហេតុដោយខ្យល់ព្យុះស៊ីក្លូនឈ្មោះAmphan បានធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋឥណ្ឌាប្រមាណជា១៣លាននាក់ និងរងផលប៉ះពាល់ផលវិស័យសេដ្ឋកិច្ចជាតិរហូតដល់ទៅ ១៣ពាន់លានដុល្លារអាមេរិក ។ កាលពីឆ្នាំ២០១៥ រលកកំដៅមួយបានបោកបក់មកលើប្រទេសឥណ្ឌា ប្រទេសប៉ាគីស្ថាន បង្កឱ្យស្លាប់មនុស្សជាច្រើនម៉ឺននាក់ តំបន់ដែលរងផលប៉ះពាល់ខ្លាំងចេញពីរលកកំដៅនោះគឺភាគខាងកើតក្រុងកាល់កាតា ក្នុងប្រទេសឥណ្ឌា ហើយនិងភាគខាងត្បូងក្រុងការ៉ាជី ប្រទេសប៉ាគីស្ថាន។ កាលណោះគេចាត់ទុកថា រលកកំដៅនេះជាគ្រោះមហន្តរាយដ៏មហិមាចំពោះប្រទេសទាំងពីរ ។

### រួមគ្នាដើម្បីជួយបន្ថយកំដៅតពផែនដី

ការគិតគូរអំពីផលប្រយោជន៍ផ្ទាល់ខ្លួនជារឿងធម្មតាទៅហើយសម្រាប់ប្រជាជាតិទាំងឡាយនៅលើផែនដី ដែលក្នុងនីយស់ទៅទៅលើប្រទេសដែលមានឧស្សាហកម្មរីកលូតលាស់ខ្លាំង ហើយព្យាយាមធ្វើនិស្សារណកម្មពីធម្មជាតិ ជាហេតុនាំឱ្យមានការបំផ្លិចបំផ្លាញធ្ងន់ធ្ងរទៅលើបរិស្ថានដូចជាការបញ្ចេញនូវឧស្ម័នផ្ទះកញ្ចក់ និងការបោនងាយអុកស៊ីងចូលទៅក្នុងទីលំហ ព្រោះតែមហិច្ឆតា អត្តទត្ថភាព ។ លុះបញ្ហាការប្រែប្រួលបរិយាកាស និងការឡើងកំដៅជាសកល បានជះផលប៉ះពាល់ដល់ប្រទេសទាំងឡាយនៅពាសពេញពិភពលោកឬយើងអាចនិយាយម្យ៉ាងទៀតថា ពេលកំពុងតែទាញប្រយោជន៍ពីបរិស្ថាន ដើម្បីប្រទេសខ្លួនហាក់ស្វាត់ឈឺង ប៉ុន្តែពេលមានទុក្ខចេញពីបណ្ដាសារបរិស្ថានវិញក៏ទទូចអំពាវនាវឱ្យពិភពលោកចូលរួមដោះស្រាយរួមគ្នាទៅវិញ? រឿងរ៉ាវពិតជាចម្លែកមែននៅលើផែនដីយើងនេះ។

អ្នកឯកទេសបរិស្ថានវិទ្យាបានព្យាករណ៍ទុកថា ប្រសិនបើពិភពលោក មានសាមគ្គីភាពទាំងអស់គ្នាកាត់បន្ថយការរំភាយចេញនូវកាបោនក្នុងរយៈពេល ១ទសវត្សរ៍ខាងមុខបន្ទៀត សីតុណ្ហភាពជាមធ្យមអាចនឹងនៅបន្តកើនត្រឹម ១.៥អង្សាររហូតដល់ឆ្នាំ ២០៤០ និងអាចបន្តកើនឡើងនូវកំដៅជាមធ្យមដល់ ១.៦ អង្សារនៅឆ្នាំ ២០៦០ ខាងមុខ ។ ប៉ុន្តែប្រសិនណាបើពិភពលោកមិនរួបរួមគ្នាដោះស្រាយរឿងនេះទេ ភពផែនដីទាំងមូលអាចនឹងកើនឡើងនូវកំដៅដល់ទៅ ២.០អង្សារនៅឆ្នាំ ២០៦០ និងកើនឡើងដល់ ២.៧អង្សារនៅដំណាច់សតវត្សរ៍យើងនេះ ៕

អនុសេនីយ៍ត្រី ច្រាក់ សម្ផស្ស



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

https://online.fliphtml5.com/vhqfg/tavz/



# សញ្ជាតិតែមួយ

១. សញ្ជាតិតែមួយ **តេជោ**លើកស្ទួយ សិទ្ធិភាស្ត្រីប្រជា
ឈប់ខ្វល់គេថោក ព្រោះចាញ់ឃោសនា ពលរដ្ឋគ្រប់គ្នា
គាំទ្រស្មោះស្ម័គ្រ ។

២. សញ្ជាតិតែមួយ អស់ល្បែងក្ដិចត្រួយ ពោលពាក្យអបលក្ខណ៍
គោរពម្ចាស់ឆ្នោត ដោយស្វាមីភក្ដិ រួមក្ដៅត្រជាក់
ស្ម័គ្រសាងកេរ្ដិ៍ឈ្មោះ ។

៣. សញ្ជាតិតែមួយ ឈប់ភ័យឈប់ព្រួយ ជួយគ្នាដោយស្មោះ
យោបល់ស្ថាបនា កិច្ចការដែលខុស គ្មានល្បិចកាយគាស់
កាច់ផ្លូវរលំ ។

៤. សញ្ជាតិតែមួយ ល្អមដល់ពេលហើយ មតិមូលផ្ដុំ
បន្ថយទុក្ខព្រួយ ភាស្ត្រនិងសង្គម ខ្មែរស្គាល់សុខជុម
រួមរស់រីករាយ ។

៥. សញ្ជាតិតែមួយ រួមគ្នាលើកស្ទួយ ប្រជាធិបតេយ្យ
ជួយគ្នាស្ថាបនា វាចារភក្ដី រួមគ្នាកែច្នៃ
ពីខុសមកត្រូវ ។

៦. សញ្ជាតិតែមួយ មិនអាងចោះពួយ ចេញទៅស្រុកក្រៅ
ជួយគ្នាដោយស្មោះ រស់នៅកក់ក្ដៅ ជុំញាតិកូនចៅ
មូលផៅសន្ដាន ។

៧. សញ្ជាតិតែមួយ គ្រប់គ្នាឈប់ព្រួយ ព្រាត់កូនប្រពន្ធ
ប្រជាធិបតេយ្យ ថ្លាថ្លៃរលូន ជាតិខ្មែរផុតសូន្យ
រុងរឿងនិរន្ដន៍ ៕

ដោយ: **ទ.ស.**



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

# សកម្មភាពប្រតិភូ ស ម ន នាំយក
## ថវិកាផ្តល់ជូនដល់គ្រួសារសព សមាជិក-សមាជិកា ដែលទទួលមរណភាព និងបាត់បង់សមត្ថភាពការងារ



**ឧត្តមសេនីយ៍ទោ ថូ ភ័ក្រ្តា** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋានច្រកទ្វារទី ២ ប្រគល់ថវិកា ស ម ន ជូនលោកស្រី សឿន សារឿន ត្រូវជាភរិយាសពលោកវរសេនីយ៍ទោ ចាន់ សំបូរ។

**ឧត្តមសេនីយ៍ទោ ប្បាត សុធី** ប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ ប្រគល់ថវិកា ស ម ន ជូនលោកស្រី ហៀង ម៉េងលី ត្រូវជាកូនស្រីសពលោកវរសេនីយ៍ទោ ពេជ្រ វណ្ណា។





**ឧត្តមសេនីយ៍ទោ អ៊ុំ សាត** អនុប្រធានគណៈកម្មាធិការមូលដ្ឋាននាយកដ្ឋានចារកម្មប្រគល់ថវិកា ស ម ន ជូនលោកស្រី គី ស្រីមុំ ត្រូវជាភរិយាសពលោកវរសេនីយ៍ទោ ចាន់ សុខា។

**ឧត្តមសេនីយ៍ទោ ហ៊ុន សុធី** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ប្រគល់ថវិកា ស ម ន ជូនលោកស្រីស៊ិន ផុន ភរិយាសពលោកអនុសេនីយ៍ត្រី សែម ឆាត។



សូមលំអោនកាយរំលែកទុក្ខយ៉ាងក្រៀមក្រំ ចំពោះមន្ត្រីនគរបាលជាតិ
ដែលបានពលីជីវិតក្នុងបេសកកម្មនានានៃបុព្វហេតុជាតិ មាតុភូមិ និង
សូមបួងសួងឲ្យវិញ្ញាណក្ខន្ធបងប្អូន ឆាប់បានទៅកាន់សុគតិភព។



៣ការពារ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

22/5/23, 10:10 AM



**ឧត្តមសេនីយ៍ត្រី ស្រ៊ី សុវណ្ណ** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំង ប្រគល់ថវិកា ស ម ន ជូនលោកព្រិន្ទបាល ទោ ផាន់ ទូច ដែល ភរិយាទទួលមរណភាព ។

**ឧត្តមសេនីយ៍ត្រី សែល ញ៉ាន** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកែប ប្រគល់ថវិកា ស ម ន ជូនលោកស្រី សេង ប៉ាវ ត្រូវជាភរិយាសពលោកវរសេនីយ៍ទោ ព្រុំ ចាន់ ។





**ឧត្តមសេនីយ៍ត្រី ឡុង គីម** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពត ប្រគល់ថវិកា ស ម ន ជូនលោក ហេង ពុធ ត្រូវជាកូនប្រុសសពលោកពលបាលឯក ហេង ណារិទ្ធ ។

**ឧត្តមសេនីយ៍ត្រី ទូច សាកល** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តសៀមរាប ប្រគល់ថវិកា ស ម ន ជូនលោកស្រី ទេព ណារិន ត្រូវជាភរិយាសពលោកអនុសេនីយ៍ឯក ណី វីរៈ ។





**វរសេនីយ៍ឯក ប៊ុត ហោង** លេខាធិការគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តរតនគីរី ប្រគល់ថវិកា ស ម ន ជូនប្អូនស្រី មាំង សូរិយា ត្រូវជាកូនស្រីសពលោកអនុសេនីយ៍ត្រី មាំង ហុង ។

**វរសេនីយ៍ឯក ទាន ប៉េងស៊ិន** អនុប្រធានគណៈកម្មាធិការមូលដ្ឋានស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ប្រគល់ថវិកា ស ម ន ជូនលោកស្រី ប៉ែន ទូច ត្រូវជាភិរយាសព លោកអនុសេនីយ៍ត្រី សេង សារ៉ុម ។





**៣កុំ ៖** -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/tavz/

អ្នកស្រី
ប៉ាល់ វណ្ណារីរក្ស

# រឿង បំភ្លេចមិនបាន



ចំណាត់ថ្នាក់លេខ១ស្ទួន ពានរង្វាន់ព្រះសីហនុរាជ ឆ្នាំ១៩៩៥

22/5/23, 10:10 AM

តមកពីលេខ ១០០

-មិនត្រូវទុកជីវិត ឱ្យចិតក្នុងសភាពខ្សត់ខ្សោយដូចពេលមុនទៀយ ពេលវេលាថ្មី ជីវិតថ្មី សំរាប់ក្មួយបានមកដល់ហើយ តើ ។ មិនណាម្តងទៀត ។ គាត់ស្រដីទាំងញញឹម

អ្នកស្រីបែរកាយចាកចេញ នាង**ចាន់** ដែលឈរស្ងៀមក្បែរគ្រែអ្នកជំងឺ បានជូនដំណើរអ្នកស្រីទៅក្រៅ ។ សមានចិត្តមនុស្សក្នុងផ្ទះ លោក **តិរត្ន** មានជានិច្ចលើរូបស្រីស្រស់ **ធីរិយា** នឹករលឹកអរគុណដល់ព្រេងវាសនា ដែលរូបនាងជួបមនុស្សល្អៗ...នាងកំព្រាធ្លាប់វេទនា លំបាក តែវាសនាមិនរត់ចោលស្រីឆ្នើមឡើយ...តើមកពីអ្វី? មិនគឺមកពីគំនិតឧត្តមដែលជានិស្ស័យធម្មជាតិភាក់តែងដល់រូបនាង ផ្សំជាមួយការអប់រំរបស់មេដ្ឋមណ្ឌលកូនឡាប ដែលមានលោកគ្រូ អ្នកគ្រូទេឬ? ...**ធីរិយា** បិទភ្នែកនឹករលឹករកពាក្យពេចន៍សំរាប់អរគុណលោកប្រុសរបស់នាង នាពេល៤ថ្ងៃខាងមុខ ។

ថ្ងៃរង់ចាំបានមកដល់ ស្ថានភាពជំងឺរបួស **ធីរិយា** បានធូស្បើយជាច្រើនបើថ្នាំល្អៗសំរុកសំរាប់ការព្យាបាល...ការយកចិត្តទុកដាក់ពីពេទ្យក៏គ្រប់គ្រាន់...ចំណីចំណុកបំប៉នសុខភាពមានគ្រប់បែបឥតខ្វះចន្លោះ...នាង**ចាន់** ក៏បានថែទាំបំរើ **ធីរិយា** ឥតទាស់ចិត្ត ថ្ពាក់ថ្ពមស្រីដូចកែវខ្លាចធ្លាក់បែក...នេះជាកត្តាបណ្តាលមកពី លោក **តិរត្ន** ។ លោកប្រុសសប្បុរស... លោកប្រុសបារម្ភពីនាង...លោកប្រុសមិនអាក្រានិយមប្រកាន់ពីកំហុសនាង... **ធីរិយា**កាន់តែអន្ទះអន្ទែងចង់ជួបលោកប្រុស ។ ឆោមឆើតគេងលើគ្រែ ទន្ទឹងរង់ចាំសុំទោស និងអរគុណដល់ **តិរត្ន** កែវភ្នែកនួនល្អងដឹកដោយរស្មីរង់ចាំសំឡឹងញើកញ្រាប់ ឆ្ពោះទ្វារបន្ទប់ ។ នាងគេងមិនលក់ រសាប់រសល់ចំឡែក... ជាមួយប្រុស អភិជនម្នាក់នេះ គេប្លែកចំពោះនាង នាងត្រូវជ្រើសរើសសំនួនប្រយោគអ្វីខ្លះ សំរាប់មនុស្សប្លែកដូចគ្នា...**ធីរិយា** បណ្តោយអារម្មណ៍ហោះហើរឥតឈប់ឈរ សមពេលនេះអវត្តមាន នាង **ចាន់** ដែលចេញទៅរកទិញចំណីសំរាប់នាងផង ធ្វើឱ្យរូបស្រីនៅតែឯង ស្ងាត់ស្ងៀមរឹងរឹតតែរង់ចាំ...

កុកៗ...ស្នូរគោះទ្វារណាន់ ។ **ធីរិយា** បាញ់នេត្រាទៅទ្វារពោល ៖

-សូមអញ្ជើញចូល ។

នៅចំពោះទ្វារបើក ពុំមែនជា **តិរត្ន**ទេ នោះជា **ភក្កដា** មិត្តរបស់នាងទៅវិញ ដីភាក់ព្រាញញឹមដោយរំជួលចិត្តជាមួយវត្តមានថែងន្យរបស់គេ ស្រីរបូតប្រយោគ ៖

-ហ្អាក **ភក្កដា**ទេតើ !

-**ធីរិយា**! ខ្ញុំនឹកឯងណាស់ណា ។

**ភក្កដា**ស្រដី ទាំងស្ទុះទៅជិតស្រីសោភា ។ ដៃ **ភក្កដា** កាន់ផ្កា១បាច់ និងថង់ក្រូច១ឡូត៍ ។ គេហុចវត្ថុទាំងនោះទៅឱ្យ **ធីរិយា** ញញឹមភ្លាប់វាចា៖

-ខ្ញុំជូន **ធីរិយា** ។ យ៉ាងម៉េចដែរ សុខភាពរបស់ឯង?

-អរគុណ **ភក្កដា** ។ សុខភាពខ្ញុំល្អដូចធម្មតាហើយ យ៉ាងយូរ ៣ឬ៤ថ្ងៃទៀត ខ្ញុំអាចជាដូចដើមវិញមិនខាន ។ សំបុត្ររបស់ **ភក្កដា** ធ្វើឱ្យខ្ញុំមានការអៀនខ្មាសចិត្តយើងណាស់ មិនគួរខ្ញុំភ្លេចពួកយើងនាមួយរយៈតូចនោះទេ...

-តែ ព្រោះអ្វី? ខ្ញុំយល់ហើយណា **ធីរិយា** ។ ផ្ទះនោះធំ និងចំឡែកមែន ឯកូនម្ចាស់ផ្ទះ តើរឹងរូសបែបណាទៅ? ទើប **ធីរិយា** ភ្លេចពួកយើងអស់រលីង ។

-ចាំថ្ងៃក្រោយ ខ្ញុំនិយាយប្រាប់ ។ " ពេលនេះខ្ញុំ សុំសួរសុខទុក្ខពួកយើងឯណោះសិនចុះ នាងពោលទាំងធ្វើមុខញញឹមៗ "

-សុខសប្បាយគ្រប់ៗគ្នា គ្រាន់តែរំខានចិត្តភ្ញិតនឹករលឹកមក **ធីរិយា** ណា ។

-ផ្តាំផ្ញើការអរគុណពួកគេផង។ ពិសេសអរគុណ **ភក្កដា**ឯងជាជាងនរណាទាំងអស់ ។

-មិនទទួលទេពាក្យអរគុណ ។ តាំងពីស្គាល់ **ធីរិយា** ពេលណាមកបើមានបាវទុកពាក្យច្រកអរគុណ មិនដឹងប៉ុន្មានបាវទេ? ពេលនេះសុំទិញគ្រវាត់ចោលណា ។

-មិនបានទេ នោះជាទម្លាប់ខ្ញុំណា ហាស់ ហាស់ " នាងសើចតិចៗ "

-លើកលែងចំពោះខ្ញុំម្នាក់ តើបានឬទេ ?

-មិនបានទេ! ហាស់ ហាស់ ។

-ហាស់ ហាស់ **ភក្កដា**

កំពុងសាសងលាយឡំស្នូរសំណើចរីករាយនៅឯខាងក្រៅ **តិរត្ន** កំពុងបោះជំហានកាន់តែមកជិតបន្ទប់ស្រស់ធីតា ។ ទ្វារបន្ទប់ចំហល្មមនឹងបង្ហាញដល់កែវភ្នែក **តិរត្ន** នូវភាពស្និទ្ធស្នាលរវាង **ភក្កដា** និង **ធីរិយា**...ឪពុក **តារី** ជ្រួញចិញ្ចើមគេមិនយល់ពី **ធីរិយា** និងប្រុសម្នាក់នោះជាអ្វីនឹងគ្នាបានជា



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា

https://online.fliphtml5.com/vhqfg/tavz/

ស្អិតម្ល៉េះ? ចរិតឆ្មើងឆ្មៃងុះភ្លែត នរៈទីងទេវមិនគួរសោះស្រីស្រស់ បំពានពាក្យសន្យាជាមួយគេ ព្រោះមុននេះអ្នកស្រី**ស៊ីថា** បានទូរស័ព្ទមកប្រាប់ **ធីរិយា** ពីម៉ោងពេលដែលនាយត្រូវមកសាកសួរដំណឹងនាង ។ ហេតុអ្វីឆោមធីតាយកពេលវេលាសំរាប់គេទៅណាត់ជួបប្រុសផ្សេងក្នុងលក្ខណៈគួរឆ្គងភ្នែកទៅវិញ? នាងជា មនុស្សប្រភេទណា បំណាងដូចម្តេចជាមួយគេ? សូម្បីអំណោយគេចំពោះរូបស្រីនួននាងសំរាំងទម្លាប់ខ្លួន ប្រឆាំងទម្លាប់មារយាទ ? មិនបានដាច់ខាត **ធិរត្ន** កើតមានភាពសោះអង្គើយដល់រូប **ធីរិយា** មិនអាចឱ្យក្មេងស្រីម្នាក់នេះឈ្នះគេឡើយ ។ ចុះម៉ែអោះ ម្តេចសរសើគេម្ល៉េះ សុទញែងតែនាងឆ្លាតវៃ មានឆន្ទៈមុះមុតលើការងារ ប៉ុន្តែពេលនេះនាងជាមនុស្សមិនគោរព ពាក្យសន្យា ។ **ធិរត្ន**សំរេចចិត្តមិនរំខាននាង និងប្រុសម្នាក់នោះទេ គេត្រូវតែត្រឡប់ទៅផ្ទះវិញ ដោយមិនចាំបាច់ជួបនាង ។ ហ៊ឹះ ស្រីរូបល្អ ឫកមិនសម គេខ្ពើមគួសមណាស់ ។ បុរសអភិជនបែរកាយត្រឡប់ក្រោយ តែមិនភ្លេចលួចមើលភ្នែកសំគាល់ **ភក្តជា** ទុកក្នុងចិត្តសិនដែរ ។ ហេតុអ្វីបង្គំប្រុសម៉ត់ចត់ដូច **ធិរត្ន** សន្និដ្ឋាន **ធីរិយា** ឥតពិចារណា ។ មនុស្សដូចគេធ្លាប់ "គិត " មុន " គូរ " ជានិច្ច តើពេលនេះអនុភាពអ្វីបញ្ឆោចិត្តគេឱ្យប្រាសចាកសភាពដើម? នេះឬ សេចក្តីផ្តើមនៃបេះដូងសំងាត់របស់បុរសឆ្មើងឆ្មៃ?...គេចាកចេញទៅទាំងមុខងាំ ។

យើងបែរមកស្តាប់ការសន្ទនារវាង **ធីរិយា** និង**ភក្តជា** ជាបន្ត យើងឮ **ធីរិយា** សួរកំលោះវ័យក្មេង ៖

-ហេតុអ្វី **ភក្តជា** ដឹងថាខ្ញុំសំរាកនៅទីនេះ?

-ខ្ញុំបានទៅរក **ធីរិយា** ឯផ្ទះ លោក **ធិរត្ន** ។ ខ្ញុំជួប អ្នកស្រីម្នាក់ គាត់ប្រាប់ខ្ញុំពី **ធីរិយា** ណាំ ។

-អូហ៍ ចុះ **ភក្តជា** មានដំណើរមកខេត្តនេះ ដើម្បីអ្វីដែរ ?

-ខ្ញុំត្រូវទៅលេងឪពុកមាម្នាក់ ឯក្រចេះ ត្បិតគាត់ផ្តាំខ្ញុំឱ្យទៅទទួលលុយ កាក់ដែលគាត់ត្រៀមចំរាប់ជួយផ្គត់ផ្គង់ខ្ញុំនាពេលខ្ញុំរៀនគរុកោសល្យ ។ ដូច្នេះខ្ញុំឆ្លៀតចូលសួរសុខទុក្ខ **ធីរិយា** តាមពាក្យសន្យាក្នុងសំបុត្រនោះអី ។

-អរគុណដល់ចិត្ត **ភក្តជា** ដែលមានចំពោះរូបខ្ញុំ ។

-អរគុណអីក៏ច្រើនម្ល៉េះ បើមកសួរសុខទុក្ខ គ្មានអ្វីជាជុំកំភួនផង ។ ស្តាយណាស់ បើខ្ញុំមានលុយ ខ្ញុំទិញស្ពឺស្ពុក ចំណីចំណុកជាច្រើនមកធ្វើវិយាតែម្តង " គេនិយាយលាយសំណើច"

-បានហើយៗ ខ្ញុំមិននិយមសម្ភារហួស ចិត្តហួសថ្លើមទេ ។ ណេក្តីយពួកយើងសុទ្ធតែខ្សត់អត់ដូចតែគ្នា ម្នាក់ៗជួយខ្លួនឯងមិនរួចទេកុំចង់ជួយខ្ញុំអី ខ្ញុំអាចរស់ស្រួលជាងមុនជាច្រើនណាំ **ភក្តជា** ។ និយាយអញ្ចឹង កក្តជាឯង ទៅក្រចេះថ្ងៃណា?

-ស្អែកនេះហើយ ត្បិតប្រញាប់វិលទៅរៀនគរុកោសល្យវិញ ។

-ជូនពរដល់ដំណើរ **ភក្តជា** ណាំ ។

-ជូនពរ សុខភាពល្អដល់ **ធីរិយា** ។ ចាំខ្ញុំត្រឡប់ពីក្រចេះ ខ្ញុំចូលលេង **ធីរិយា** ម្តងទៀត ។

-អរគុណ ។

-លាសិនហើយ ។

-ទៅចុះ **ភក្តជា** ។

បាត់រូប **ភក្តជា** **ធីរិយា** វិលមករកការរង់ចាំលោក **ធិរត្ន** ... ម៉ោងជិតប់ហើយ មេឃរកកលងងិតស្រាលៗ យប់យន់ ប្រុងប្រៀបរៀបចំនាទីមកជំនួសទិវា...ម្តេចបាត់រូបគេយូរម្ល៉េះ? អ្នកស្រីគ្រប់គ្រងផ្ទះ នោះជាវេលាដែលនាងត្រូវសុំទោស និងអរគុណដល់រូបគេ...ចុះថ្មើរនេះនៅតែបាត់រូបលោកប្រុស? នាងចាំស្រី ទន្ទឹងឥតយល់ស្របមោលបុរសអភិជន ។

ការរង់ចាំបានបន្តាយរហូតដល់ ៥ថ្ងៃ ក៏ **ធីរិយា** ឥតបានជួបភក្រ្ត **ធិរត្ន** ។ ការយកចិត្តទុកដាក់មកលើរូបនាង មានសភាពដូចពេលមុនដដែល មានតែរូបអ្នកស្រីគ្រប់គ្រងផ្ទះដែលចេញចូលសាកសួរសុខទុក្ខ និងផ្តល់ការថែទាំដល់ស្រីកំព្រាឯរូបបុរសសង្ហាឥតដែលបង្ហាញមុខចំពោះភ្នែក **ធីរិយា** សោះឡើយ ដំណឹងអ្វីពីរូបគេក៏គ្មាន សូម្បីអ្នកស្រី **ស៊ីថា** ឥតដែលរំលឹកពីអ្វីៗ ដែលទាក់ទងលោកប្រុស និងរូបនាងដែរ ។ **ធីរិយា** មានការទន្ទឹងតែឱបដោយក្តីងឿងឆ្ងល់លាយឡំសេចក្តីខ្លាចចិត្តលោកប្រុសងក់ងាប់ក្នុងទ្រូង ។

## ខណ្ឌ៧

**ធីរិយា** វិលត្រឡប់មកទីលំនៅ លោក **ធិរត្ន** ចំនួន ១៥ថ្ងៃដំបីនាងជាសះស្បើយដូចដើម សុខភាពមាំមួន គ្មានអ្វីគួរភ័យព្រួយ ។ អស្សៀលត្រជាក់ **ធីរិយា** ឈរអោនចរឹងបង្អួចបន្ទប់...សំឡឹងទៅមែកផ្កាម្លូលបក់បោកតាមវាយោយោលយោគ



ពាការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល

ទោទន់ទេរាំងាក់គ្នា...ស្លឹកបុប្ផាបក់រវិចៗបង្អួត សោភ័ណខៀវខ្ចីស្រស់បំព្រង...ក្លិនក្លែបក្រអូបក្រអៃបដះគន្ធពិដោរល្អយល្អប់ហើរមកប៉ះប្រឡៅងនាសាស្រីកំព្រា ។ ម្ដងម្កាលផ្លើមកន្លងទៅ **ធីរិយា** បែរមកយឹកៗស៊ាំឡឹងស្រះស្រង់ពពុះទឹកព្រិចកើតព្រោះហ្វូងមច្ឆាហែលឆ្លេឆ្លាប្រណាំងកាយគ្នាហាង់កាត់ផ្ទៃទឹក...ផ្កាវិចង់ឯកកន្ទុកពីផ្ទៃវារី ឈរស៊ាំញញឹមស៊ាំនៃងរាងគួរគយគន់មើលចុះខ្លះរីក ខ្លះក្រពុំ ជូនខ្យល់បក់រូវ វារីផាតិកំភើក ម្ដងទៅលិចម្ដងទៅកើត...រអ្វីៗនាពេលសាយណ្ហសម័យហៀបទន់ទាបសែនក្រដាក់ក្រកាលទាក់ភ្នែក **ធីរិយា** ពន់ពេក ។ ប៉ុន្តែទឹកមុខឆោមឆើតពោរពេញដោយកង្វល់ នាងមិនយល់ចិត្ត លោកប្រុសម្ដេចគ្មានឱកាសជួបនាង? ប៉ុន្មានថ្ងៃមកហើយតាំងពីនាងនៅព្យាបាលក្នុងមន្ទីរពេទ្យ អ្នកស្រីតែងតែផ្ដល់ចំឡើយក្នុងន័យលោកប្រុសរវល់ លោកមិនទំនេរឥតឱកាសដើម្បីជួបនាង...ឱ! ឬកគេធំណាស់ហ្ន៎?សំណួរមារនាងគ្មានន័យចំពោះរូបគេទេ? ឬមួយគេរវល់មែន?ចំពោះ រូបនាង **ធីរិយា** ព្យាយាមសុំការអនុញ្ញាតពីអ្នកស្រី ក្នុងបំណងជួបបុរសអភិជន ទោះជាត្រូវពន្យាពេលដល់ថ្ងៃណាក៏ដោយ ។

ស្អែកឡើងជាថ្ងៃទីពីរ ដែល **ធីរិយា** ចេញពីមន្ទីរពេទ្យទិវាថ្មីនេះស្រីកំព្រាចាប់បង្រៀននាងតូច **តារី** ។ ចរិតក្មេងឋានៈនៅតែរឹងរូសវាក្រញូនឡេលមិនព្រមរៀន ។ អ្នកគ្រូក្មេងបបួលវាស្ដាប់ព្យ៉ាណូ វាបែរជាទាមទារនាងឱ្យគូររូប ដឹកកំព្រាបំពេញចិត្តសិស្ស ។ រូបគំនូរ **ធីរិយា** ជារូបកូនផ្ទះយ៉ាងតូចច្រឡឹងល្អប្រណីតមានបន្ទប់៣ គឺបន្ទប់គេង បន្ទប់រៀន និងបន្ទប់សម្រាប់ញ៉ាំបាយ រូបគំនូរមានចំណងជើងថា " ផ្ទះ **តារី** " ក្នុងបំណងជំរុញក្មេងឱ្យអានអក្សរភ្ជាប់រូបនោះ ក្បិត **តារី** ចេះអានអក្សរខ្លះៗ និងបូកលេខ តាំងពីមុនដីកា **ធីរិយា** មកបង្រៀននាងម្ល៉េះ ។ បន្ទាប់ពីគូររូបផ្ទះ អ្នកគ្រូអង់អាចធ្នក់ចាប់ឯកបន្ទប់នីមួយៗរបស់ផ្ទះ គំនូរមកគូរបង្ហាញសិស្សច្រម៉ក់ ។ នាងគូរពីសម្ភារផ្សេងៗដែលត្រូវដាក់ក្នុងបន្ទប់នីមួយៗ ។ បន្ទាប់មកនាងប្រើល្បិចឱ្យសិស្ស ក្បាលខូចរាប់ បូក ដក សម្ភារតាមបន្ទប់ទាំងនោះ ។ ការសិក្សាភ្ជាប់ជាមួយល្បិចអូសបន្លាយរហូតដល់ម៉ោងបញ្ចប់ ។

ពេលបរិភោគ **តារី** និងឪពុកញ៉ាំបាយផ្សេងពី **ធីរិយា** និងអ្នកស្រី **ស៊ីថា** រីឯពួកបំរើត្រូវហូបចុក នាពេលជនទាំង៤បរិភោគរួច ។ នៅតុបាយអ្នកស្រីស៊ីថាស្រដីទាំងញញឹម ៖

-យប់នេះនៅវេលាម៉ោង៧ លោកប្រុសអនុញ្ញាតឱ្យក្មួយជួបគាត់ ។

-អរគុណអ្នកមីង ។

-សុខភាពក្មួយ ដូចម្ដេច ? លោកប្រុសចង់ឃាត់នាងក្នុងបំណងមិនទាន់ឱ្យនាងបង្រៀនស្រីនាងណា៎ ។

-ចាស មិនអីទេអ្នកមីង សុខភាពខ្ញុំបានដូចដើមហើយ ។ រូបខ្ញុំជំពាក់គុណលោកប្រុស បើខ្ញុំអង្គុយអស់នឹងនាទីខ្លួន ជាប្រការមិនគប្បីទេអ្នកមីង ។

-តែស្រីនាងជាក្មេងឋានៈ ដូច្នេះកិច្ចការបង្រៀនរបស់នាងអាចនឹងប៉ះពាល់សុខភាពណា៎ ។

-ចាស ខ្ញុំធ្លាប់ជួបការលំបាកវេទនាជាងនេះរាប់រយដង ។

ស្រីទាំងពីរចេះតែបន្តការសាសងឥតដាច់សូ លុះត្រាតែចប់ការបរិភោគ ទើបគេបំបែកគ្នាទៅសំរាករៀងខ្លួន ។

ម៉ោង៧ល្ងាច **តិរត្ន** កំពុងអង្គុយពិនិត្យបញ្ជីទំនិញក្នុងបន្ទប់សំរាប់នាយធ្វើការ...សំឡេងព្យ៉ាណូបទ " ស្នេហ៍ដូចដើមមេឃ "ហើរកាត់រលកអាកាសមកប៉ះសោតភាប្រុសប្រាណស្ទុះតង្រ្គិនឆក់នរ:ឱ្យផ្ទៀងស្ដាប់យ៉ាងលង់អារម្មណ៍...ចំណាំងនិងទំនោរទាញកាយគេឱ្យរំកិលទៅរកប្រភពសូរសៀងចម្រៀងនិងព្យ៉ាណូ...ប្រាណ **តិរត្ន** មកដល់កៀកជណ្ដើរ ដែលចុះពីជាន់ទីមួយចក្ខុគេយល់រូប **ធីរិយា** កំពុងចុចព្យ៉ាណូនិងបន្លឺសំនៀងយ៉ាងក្រអៅ ដោយមានកូន **តារី** ជាអ្នកស្ដាប់...ទឹកមុខ **តិរត្ន** ផ្លាស់ប្តូរតាមអត្ថន័យចម្រៀង...នេត្រាភ្លូង់តំរង់ **ធីរិយា** យ៉ាងចំឡែកមុខបុរសស្រពោនកែវភ្នែកបង្កប់ភាពស្រងូតដូចពាក្យពេចន៍តំរូញរបស់ចម្រៀងគេឈរស្ដាប់...គេស្រវេះស្រវោច...គេភ្លឹក...គេប្លែក...

នារីសោភាម្នាក់ មានវ័យប្រមាណ២៥ឆ្នាំ ប្រដាប់កាយក្នុងសំលៀកបំពាក់ធ្វើពីក្រណាត់ធុនថ្លៃរូបកាយនួននាងត្រោបលំអរដោយអលង្ការមានតំលៃពាសពេញកាយ ។ ស្រីល្អមុខញញឹមដើរចូលមករក **តិរត្ន** នេត្រានាងសំឡឹងបុរសអភិជនបបូរមាត់កំភើកដោយរំភើរ ៖

-សួស្ដី បង **តិរត្ន**!

សំឡៃវាចា ពញ្ញាក់ **តិរត្ន** ឱ្យភើតុកពីអន្លង់អណ្តែតអណ្ដូង

តទៅលេខក្រោយ



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា



តមកពីទំព័រ ២០

**ឯកឧត្តម ម៉ៅ ធនិន អភិបាលខេត្ត.....**

ទេសចរណ៍ ។ វិស័យសក្តានុពលរបស់ខេត្តមាន អំបិល រោងចក្រស៊ីម៉ង់ត៍ វារីអគ្គិសនី កំពង់ផែ កសិកម្ម នេសាទសមុទ្រ និងទេសចរណ៍ ។

ឯកឧត្តម **ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តកំពត ដែលទើបទទួលបានការតែងតាំងថ្មី ក៏បានធ្វើការប្តេជ្ញាអនុវត្តឱ្យមានប្រសិទ្ធភាពនូវកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា ដោយផ្តល់កិច្ចសហការល្អជាមួយក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពត ជាពិសេសប្តេជ្ញាអនុវត្តរាល់សេចក្តីសម្រេចគោលនយោបាយ ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំដែលបានដាក់ចេញដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។





ជាងនេះទៅទៀត ឯកឧត្តម ក៏បានប្តេជ្ញាអនុវត្តឱ្យបានម៉ឺងម៉ាត់នូវយុទ្ធសាស្ត្រគន្លឹះ និងវិធានការនានា ដែលរាជរដ្ឋាភិបាលបានដាក់ចេញក្នុងការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ ជាពិសេស



៣ការពារ ៖ -ពាក់ម៉ាស់ -លាងដៃឲ្យបានញឹកញាប់ -គម្លាតសុវត្ថិភាពបុគ្គល






មេរោគបំប្លែងខ្លួនថ្មី ប្រភេទ ដែលតា (Delta) តាមរយៈការចាត់វិធានការរដ្ឋបាល និងវិធានការសុខាភិបាលចាំបាច់ទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាពខ្ពស់សម្រាប់ធានាប្រក្រតីភាពនៃការរស់នៅតាមបែបគន្លងថ្មី របស់បងប្អូន ប្រជាពលរដ្ឋ ។

អញ្ជើញសំណេះសំណាលក្នុងពិធីនោះ **សម្តេចក្រឡាហោម** បានមានប្រសាសន៍ថ្លែងនូវការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ ឯកឧត្តម **ជាវ តាយ** អតីតអភិបាលនៃគណៈអភិបាលខេត្តកំពត ដែលត្រៀមខ្លួនចូលកាន់មុខតំណែងជាអភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ ដែលកន្លងមកបានធ្វើឱ្យខេត្តកំពត មានការរីកចម្រើនគួរឱ្យកត់សំគាល់ ។

ជាមួយគ្នានេះដែរ **សម្តេចក្រឡាហោម** បានស្នើដល់គណៈអភិបាល ក្រុមប្រឹក្សា កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋនៅក្នុងខេត្តកំពត ទាំងមូលរួមគ្នាផ្តល់នូវការគាំទ្រ ឯកឧត្តម **ម៉ៅ ធនិន** ដើម្បីមានលទ្ធភាពបន្តបេសកកម្មបម្រើប្រទេសជាតិ ក្នុងក្របខណ្ឌខេត្តកំពត ឱ្យទទួលបានជោគជ័យជាបន្តទៅមុខទៀត ។ ដោយឡែកក្នុងបរិបទជំងឺកូវីដ-១៩នេះ **សម្តេចក្រឡាហោម** ក៏បានអំពាវនាវឱ្យប្រជាពលរដ្ឋក្នុងខេត្តកំពត និងទូទាំងប្រទេស ត្រូវរៀនរស់ជាមួយកូវីដ-១៩ ដោយត្រូវអនុវត្តតាមវិធានការរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ៣កុំ ៣ការពារឱ្យបានជាប់ជាប្រចាំ ៕



៣កុំ ៖ -កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល -កុំទៅកន្លែងមនុស្សច្រើនកុះករ - កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា


SOKIMEX INVESTMENT GROUP
ក្រុមហ៊ុន សុគីមិច អ៊ិនវេសមេន គ្រុប
SOKIMEX INVESTMENT GROUP CO., LTD.
សណ្ឋាគារ និងរមណីយដ្ឋានសុខា
Sokha Hotels & Resorts
+855 23 91 91 91
បូកគោ
ក្រុមហ៊ុនបូកគោហ្វាម ឯ.ក
Bokor Farm Co.,Ltd.
+855 88 2636358 | +855 88 9494614
SOKIMEX
ស្ថានីយប្រេងឥន្ធនៈសុគីមិច
Sokimex Petroleum Station
SOKHA
ក្រុមហ៊ុនសុខារៀលអ៊ីស្តេត ឯ.ក
Sokha Real Estate Co., Ltd.
+855 98 200 777
#22 Kramuon Sar,Sangkat Phsar Thmey 2, Daun Penh, Phnom Penh Cambodia
Tel: (855) 23 998 918,Fax: (855) 23 998 920| E-mail: info@skmig.com | Website: www.skmig.com